មជ្ឈមណ្ឌលឯកសារកម្ពុជា

**BBI0090**

# សម្ភាសន៍ជាមួយឈ្មោះ យូ សារ៉េន ភេទស្រី អាយុ៥៦ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ ពេទ្យ

## មុខងារបច្ចុប្បន្នៈ កសិករ

## ស្រុកកំណើតនៅភូមិស្វែង ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ

## សព្វថ្ងៃរស់នៅភូមិភ្នំព្រឹក្ស ឃុំភ្នំព្រឹក្ស ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង

## ថ្ងៃទី២០ ខែមិនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០១:១៣:៣៥

## ៤២ទំព័រ

វណ្ណៈ : មីងខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមកដល់ភូមិមីងនេះគឺចង់ដឹងពីប្រវត្តិរឿងរ៉ាវនៅក្នុងភូមិ និងប្រវត្តិផ្ទាល់របស់មីងខ្លះ និងសម័យឆ្លងកាត់កន្លងមក ។ ហើយយើងចង់ដឹងថា ពីមុនមកនៅម្តុំនេះមានភូមិកំណើតអីដែរអត់ ហើយព្រៃ របៀបម៉េច ហើយក្រោយមកមានផ្លូវ១ជាតិ ហើយក៏មានផ្ទះសម្បែងអីកើតឡើងនៅ ពេលណា ពេលផ្តាច់ខ្លួនអីវាមានលក្ខណៈយ៉ាងម៉េច ពិបាកជាងមុន ឬក៏ស្រួលជាងមុន ខ្ញុំចង់ដឹងប្រវត្តិអស់នឹង ដើម្បីចងក្រងជាសៀវភៅ ឲ្យក្មេងជំនាន់ក្រោយបានដឹង ។ បើសិនជាយើងមិនបាននិយាយរឿងរ៉ាវទាំងអស់នឹងទេ ពេលយើងមនុស្សយើងស្លាប់៣០-៤០ឆ្នាំទៀត អាចស្លាប់ទៅបាត់ទៅ វាប្រវត្តិនឹងទៅបាត់ទៅ ប្រវត្តិនឹងវាកប់ទៅតាមនឹងហើយ ។ ចឹងបទសម្ភាសន៍ខ្ញុំជាមួយមីង តើមីងអនុញ្ញាតិឲ្យយកទៅសរសេរជាសៀវភៅ ឲ្យក្មេងបានដឹងបានឮបានទេ?

សារ៉េន : មិនដឹងម៉េចទេ ។

វណ្ណៈ : បទសម្ភាសន៍ខ្ញុំជាមួយមីង កំពុងសន្ទនានឹងឲ្យអនុញ្ញាតឲ្យខាងខ្ញុំយកទៅសរសេរជាសៀវភៅ បោះពុម្ពជាសៀវភៅបានដឹងបានឮបានទេ?

សារ៉េន : បាន ។

វណ្ណៈ : ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង១ឈ្មោះអីដែរ?

សារ៉េន : ខ្ញុំឈ្មោះ យូ សារ៉េន ។

វណ្ណៈ : មីងអាយុប៉ុន្មានហើយរាល់ថ្ងៃនេះ?

សារ៉េន : ឈ្មោះ នូ ណា ។

វណ្ណៈ : គាត់អាយុប៉ុន្មានហើយរ?

សារ៉េន : អាយុដំណាលគ្នា៥៦ ។

វណ្ណៈ : មីងមានកូនប៉ុន្មាននាក់?

សារ៉េន : កូន១ ។

វណ្ណៈ : ស្រី ប្រុស?

សារ៉េន : ស្រី ។

វណ្ណៈ : ឪពុកមីងឈ្មោះអី?

សារ៉េន : ឪពុកខ្ញុំឈ្មោះ យូ គ្រីប ។

វណ្ណៈ : យូ គ្រីប?

សារ៉េន : ចា៎!

វណ្ណៈ : ម្ដាយ?

សារ៉េន : ង៉ែត រុន ។

វណ្ណៈ : ចុះគាត់ទាំង២សព្វថ្ងៃនៅរស់ដែរ ឬក៏នៅ?

សារ៉េន : ស្លាប់ៗអស់ហើយ ។

វណ្ណៈ : ស្លាប់ជំនាន់ណា?

សារ៉េន : គាត់ឪពុកខ្ញុំស្លាប់៧៧ ហើយម៉ែខ្ញុំទើបស្លាប់ឥឡូវនេះដែរ ។

វណ្ណៈ : ឪពុកស្លាប់?

សារ៉េន : ស្លាប់ឆ្នាំ៧៧ ។

វណ្ណៈ : គាត់ស្លាប់៧៧ គាត់ស្លាប់ដោយសារជម្ងឺ ឬម៉េច?

សារ៉េន : ចា៎! ដោយជម្ងឺ ។

វណ្ណៈ : ចុះបងប្អូនមីងមានប៉ុន្មាននាក់?

សារ៉េន : បងប្អូនខ្ញុំមាន៧នាក់ ។

វណ្ណៈ : ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សារ៉េន : ស្រី៣ ប្រុស៤ ។

វណ្ណៈ : ស្រី៣នេះ?

សារ៉េន : ចា៎!

វណ្ណៈ : សព្វថ្ងៃនៅសល់ប៉ុន្មាន?

សារ៉េន : សព្វថ្ងៃនៅសល់ប្រុស១ ស្រី៣ ។

វណ្ណៈ : នៅសល់៤នាក់នេះ?

សារ៉េន : ចា៎! សល់៤ ស្លាប់នៅក្នុងសង្គ្រាមវ៉ៃជំនាន់លន់ នល់អស់៣ ។

វណ្ណៈ : ស្លាប់សង្គ្រាមលន់ នល់?

សារ៉េន : ចា៎! វ៉ៃជាមួយលន់ នល់ អស់៣ ប្រុស៣នាក់ ។

វណ្ណៈ : កាលនឹងវ៉ៃជាមួយទាហានលន់ នល់?

សារ៉េន : សង្គ្រាម៥ឆ្នាំ ។

វណ្ណៈ : ចឹងមីងបានរៀនសូត្រត្រឹមណាដែរ?

សារ៉េន : ខ្ញុំរៀនថ្នាក់ទី៩ពីសង្គម ។

វណ្ណៈ : ទី៩ចាស់?

សារ៉េន : ចា៎!

វណ្ណៈ : មីងរៀននៅសាលាណា?

សារ៉េន : ខ្ញុំរៀននៅស្រុក សាលាវត្តត្នោតជុំ នៅក្នុងខេត្តតាកែវ ។

វណ្ណៈ : សាលាត្នោតជុំ?

សារ៉េន : ចា៎! នៅស្រុកនោះ ។

វណ្ណៈ : ស្រុកអីគេអានឹង?

សារ៉េន : ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ ។

វណ្ណៈ : ចឹងភូមិកំណើតមីង?

សារ៉េន : ភូមិកំណើតនៅភូមិស្វែង ឃុំត្រពាំងធំ ។

វណ្ណៈ : ភូមិ?

សារ៉េន : ស្វែង ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ ។

វណ្ណៈ : ចឹងសព្វថ្ងៃមីងនៅភូមិអី?

សារ៉េន : បច្ចុប្បន្នខ្ញុំនៅភូមិភ្នំព្រឹក្ស ឃុំភ្នំព្រឹក្ស ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង ។

វណ្ណៈ : ចឹងមីងៗរៀនបានត្រឹមថ្នាក់ទី៩ ហេតុអីបានមីងឈប់រៀន ដោយសារមូលហេតុអី?

សារ៉េន : នែក! កើតសង្គ្រាមៗឈប់រៀនឆ្នាំ៧០ កើតសង្គ្រាមត្រូវតែចូលក្រុងអស់ហើយ ។

វណ្ណៈ : ឆ្នាំ៧០កើតរដ្ឋប្រហារ?

សារ៉េន : កើតរដ្ឋប្រហារនឹង ឈប់រៀន ។

វណ្ណៈ : កើតរដ្ឋប្រហារនឹង មីងឈប់រៀនចូលទៅណាទៀត?

សារ៉េន : ខ្ញុំឈប់រៀនបាន២ឆ្នាំ គេហៅឲ្យចេញតស៊ូ គេបំផុសពួកកូនសិស្ស ឲ្យចេញមកតស៊ូ ។

វណ្ណៈ : ចឹងឆ្នាំ៧២មីងចូលតស៊ូ?

សារ៉េន : …ចូលតស៊ូ ចូលធ្វើពេទ្យ ។

វណ្ណៈ : ចឹងនៅក្នុងបងប្អូនមីងដូចថាចលនានឹង ចូលព្រៃនឹងប៉ុន្មាននាក់?

សារ៉េន : ចូលកងទ័ព សង្គ្រាម៥ឆ្នាំកងទ័ព៣នាក់ ។

វណ្ណៈ : ៣នាក់?

សារ៉េន : ហើយខ្ញុំធ្វើពេទ្យម្នាក់៤នាក់ ខ្ញុំធ្វើពេទ្យពួកនិរតី ។

វណ្ណៈ : ……(ស្តាប់មិនបាន) ?

សារ៉េន : ប៉ុនស្លាប់ទាំង៣ ។

វណ្ណៈ : ពេទ្យម្នាក់ ។ កាលនឹងកាលដែលមីងចូលនឹងចូលដោយស្ម័គ្រចិត្ត ឬក៏ចូលដោយសារតាមការអំពាវនាវរបស់សម្តេចសីហនុ ដែលឲ្យកូនចៅចូលព្រៃម៉ាគី ដើម្បីប្រឆាំងជាមួយខាងលន់ នល់ អីចឹង ឬយ៉ាងម៉េច?

សារ៉េន : មានគេបំផុសបំផុលឲ្យចូលតស៊ូ ខ្ញុំអត់ដឹងដែរ ព្រោះនៅតូចៗ ។

វណ្ណៈ : អត់ដឹងដែរ ចឹងអត់បានឮសម្តេចប្រកាសអីទេ?

សារ៉េន : អត់ដែលមានដូចថាបងៗរៀមច្បងចឹង គេចេញតស៊ូ គេមកបំផុសតាមភូមិឲ្យចេញតស៊ូ ហើយខ្ញុំក៏ចេញមកលួចមកម៉ែឪអត់ដឹងផង ។

វណ្ណៈ : ចឹងដល់ពេលមីងចេញតស៊ូ មីងចូលតស៊ូនៅក្នុងភូមិឃុំនឹងដដែល ឬក៏គេឲ្យទៅព្រៃឆ្ងាយពីភូមិកំណើត?

សារ៉េន : ខ្ញុំមកឆ្ងាយ ខ្ញុំមកនៅ ។

វណ្ណៈ : ឆ្ងាយនៅណា?

សារ៉េន : មកនៅពេទ្យភូមិភាគនិរតី ជិតផ្លូវជាតិលេខ៤នេះ នៅពេទ្យភូមិភាគ ។

វណ្ណៈ ៖ និរតីជិតផ្លូវជាតិលេខ៤?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចឹងកាលជំនាន់នឹង មីងឃើញទេ ពេលដែលកើតសង្គ្រាម ពេលទាហានខ្មែរក្រហមច្បាំងទាហានជាមួយសេនាប្រមុខលន់ នល់ នឹង តើមីងជាអ្នកពេទ្យ មិនមែនជាទាហាន?

សារ៉េន ៖ អត់ទេ ខ្ញុំពេទ្យ ។

វណ្ណៈ ៖ មីងឃើញសកម្មភាពដូចថារបួសទាំងខាងលន់ នល់ ទាំងខាងខ្មែរក្រហម មានរបួស មានស្លាប់ច្រើនទេ កាលជំនាន់នឹង?

សារ៉េន ៖ ស្លាប់ច្រើនៗណាស់ ។

វណ្ណៈ ៖ ខាងខ្មែរក្រហមក៏ស្លាប់?

សារ៉េន ៖ ខាងទាហានលន់ នល់ ក៏ស្លាប់ ។

វណ្ណៈ ៖ ស្លាប់ច្រើន?

សារ៉េន ៖ ចា៎! ស្លាប់ច្រើន បែបសមរភូមិមួយស្លាប់ច្រើនណាស់ ។

វណ្ណៈ ៖ ចឹងពេលធ្វើសង្គ្រាមរយៈពេលប៉ុន្មានឆ្នាំនឹង ស្លាប់ច្រើនដូចគ្នា?

សារ៉េន ៖ ច្រើន ។

វណ្ណៈ ៖ ស្លាប់?

សារ៉េន ៖ សង្គ្រាម៥ឆ្នាំនឹងស្លាប់ច្រើនណាស់ ។

វណ្ណៈ ៖ ស្លាប់ខ្មែរតែមួយ?

សារ៉េន ៖ ចា៎! ខ្មែរតែមួយ ។

វណ្ណៈ ៖ ស្លាប់ទាហានរំដោះ និងទាហានលន់ នល់?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចឹងកាលនឹង កាលមីងចូលព្រៃនឹង កាលនឹងមានទម្លាក់គ្រាប់បែកមានអីនេះ សម័យទម្លាក់គ្រាប់បែក?

សារ៉េន ៖ មាន បេ៥២ទម្លាក់ៗមហាទម្លាក់ ។

វណ្ណៈ ៖ ចឹងពេលទម្លាក់នឹងមានត្រូវផ្ទះអ្នកស្រុកអ្នកភូមិខ្លះ?

សារ៉េន ៖ ត្រូវៗមន្ទីរពេទ្យ ត្រូវអ្នករបួសមកពីសមរភូមិនៅមន្ទីរពេទ្យនឹងក៏ត្រូវ ពេទ្យក៏ត្រូវស្លាប់យន្តហោះបេ៥២ ។

វណ្ណៈ : ផ្ទះសម្បែងដែរ?

សារ៉េន : ចា៎!

វណ្ណៈ : ចឹងពេលវ៉ៃនឹងតើខាងលន់ នល់ ដែលចាប់បានទាហានខ្មែរក្រហម ហើយទាហានខ្មែរក្រហម ដែលចាប់បានទាហានលន់ នល់ បានដែរអត់?

សារ៉េន : ខ្ញុំអត់សូវដឹងទេខាងនឹង ព្រោះខ្ញុំនៅពេទ្យ ។

វណ្ណៈ : ពេទ្យ?

សារ៉េន : ចា៎! ដឹងថារបួសមកម៉ង ខាងណាក៏សង្គ្រោះដែរ ។

វណ្ណៈ : ចឹងបងមីង៣នាក់ស្លាប់នៅក្នុងពេលសង្គ្រាមនឹង សង្គ្រាមប្រហែលឆ្នាំណា?

សារ៉េន : ស្លាប់៧៣ ៧៤នឹង មុនរំដោះ១ឆ្នាំ៧៥ មុនវ៉ៃបែកភ្នំពេញ ស្លាប់មុនវ៉ៃបែកភ្នំពេញ ។

វណ្ណៈ : ម៉េចបានគាត់ស្លាប់ម្តង៣?

សារ៉េន : អត់ទេ នៅកងខុសគ្នា ។

វណ្ណៈ : ចុះម៉េចក៏ស្លាប់?

សារ៉េន : ចុះស្លាប់ឆ្នាំខុសគ្នា មួយវ៉ៃ..........កងខុសគ្នា ។

វណ្ណៈ : តែស្លាប់មិនទាន់បានចូលភ្នំពេញ ស្លាប់ទាំងអស់?

សារ៉េន : ចា៎! ស្លាប់ ។

វណ្ណៈ : មីងដឹងថាស្លាប់ដោយសារត្រូវគ្រាប់ ឬស្លាប់ដោយសារអី?

សារ៉េន : ស្លាប់ចូលសមរភូមិ ។

វណ្ណៈ : ចឹងមានន័យថាសង្គ្រាមបានធ្វើឲ្យជីវិតមនុស្សស្លាប់.....។ ចុះមីងនៅដល់ពេទ្យកន្លែងពេទ្យ នឹងពីណាដឹកនាំ?

សារ៉េន : ពេទ្យកាលជិតទាន់សង្គ្រាម៥ឆ្នាំនឹង?

វណ្ណៈ : បាទ! សង្គ្រាមអត់ទាន់ចូលដល់៧៥ខ្មែរក្រហមចូលទេ ។

សារ៉េន : នែក! ប្រធានពេទ្យខ្ញុំ ប្រធានភូមិភាគនឹង ឈ្មោះ គាកង គាត់មកពីហាន់ណូយ ប៉ុនរឿងត្រកូលគាត់ខ្ញុំអត់ស្គាល់ទេ គាត់ប្រធានមន្ទីរពេទ្យ ។

វណ្ណៈ : ប្រធានមន្ទីរពេទ្យ?

សារ៉េន : គាកង ។

វណ្ណៈ : គាកង នឹងវៀតណាមទេចឹង?

សារ៉េន ៖ ចា៎! ប្រពន្ធគាត់ឈ្មោះ សំ ។

វណ្ណៈ ៖ តែឈ្មោះខ្មែរ?

សារ៉េន ៖ ឈ្មោះគាត់មកពីវៀតណាមទាំងអស់ មកធ្វើប្រធានពេទ្យនឹង គាត់ទៅរៀននៅនឹង ។

វណ្ណៈ ៖ ប្រពន្ធឈ្មោះ សំ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចឹងនៅក្នុងសម័យខ្មែរក្រហម ៧២ ៧៣ ៧៤នឹង មានប្រធានពេទ្យជាវៀតណាម?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ហើយមកគ្រប់គ្រងនៅតំបន់និរតីនឹង?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ តែក្រោយមកអ្នកតាកង ហើយយាយសំនឹងទៅណា?

សារ៉េន ៖ គេចាប់អស់ ។

វណ្ណៈ ៖ គេចាប់?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចាប់គាត់ឆ្នាំណា?

សារ៉េន ៖ នែក! ចាប់គាត់ឯករាជ្យហើយនឹង ។

វណ្ណៈ ៖ ឯករាជ្យហើយ?

សារ៉េន ៖ ចា៎! ដូច៧៦ ៧៥ ៧៦តាមមើលភ្លេចហើយ យូរដែរហើយ ។

វណ្ណៈ ៖ ៧៥ ៧៦?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ព្រោះអីកាលនឹងខ្មែរក្រហម ខាងទាហានខ្មែរក្រហមក៏ពឹងខាងវៀតណាមដែរ ហើយខាងទាហានលន់ នល់ ក៏ទៅពឹងវៀតណាមដែរ ។ វៀតណាមធៀវគឺខាងត្បូង ជាមួយពឹងខាងជើងខាងខ្មែរក្រហម ពឹងដូចគ្នា ប៉ុន្តែក្រោយមកខ្មែរក្រហមឲ្យវៀតណាមទៅស្រុកវិញឆ្នាំ ៧៣ ។

ដោយសារថាខ្មែរក្រហមយល់ថាកម្លាំងមានគ្រប់គ្រាន់ហើយដែលនៅជាមួយទាហាន លន់ នល់នេះ ។ ចឹងនៅពេលដែលខ្មែរក្រហមទទួលជ័យជំនះនៅឆ្នាំ៧៥ភ្លាម គេបញ្ជូនមីងទៅណា?

សារ៉េន : គេផ្លាស់ខ្ញុំឲ្យទៅធ្វើពេទ្យនៅកោះកុង ។

វណ្ណៈ : ចឹងឆ្នាំណាមីងទៅកោះកុង?

សារ៉េន : ខ្ញុំថ្ងៃ១ខែ១ឆ្នាំ៧៥ ទៅនៅពេទ្យកោះកុង ។

វណ្ណៈ : ទៅធ្វើពេទ្យកោះកុងវិញ?

សារ៉េន : ចា៎! គេបំបែកពេទ្យភូមិភាគ បែកទៅតាមខេត្ត ។

វណ្ណៈ : តែដូចជាមីងធ្វើពេទ្យធ្វើអីចឹង អាហារហូបចុកអីមិនបញ្ហាទេ ក៏មានបញ្ហាខ្វះខាតដែរ?

សារ៉េន : ខាងជីវភាព ខាងមន្ទីរពេទ្យមិនសូវខ្វះខាតប៉ុន្មានទេ ព្រោះយើងទទួលអ្នកសំខាន់ៗច្រើន ។

វណ្ណៈ : ចឹងពី៧៥នេះដល់៧៩នេះ ដល់៧៩មីងនៅណា?

សារ៉េន : នៅកោះកុង ។

វណ្ណៈ : នៅកោះកុងរហូត?

សារ៉េន : ចា៎! ហើយបានរត់មក ។

វណ្ណៈ : ចឹងពេទ្យនៅកោះកុងនឹងពីណាប្រធានពេទ្យ?

សារ៉េន : មានប្រធាននឹង ប៉ុនឥឡូវគាត់ស្លាប់បាត់ហើយ ឈ្មោះអ៊ឹភួងៗ គាត់ប្រធាននៅកោះកុង នឹង ប៉ុនគាត់ស្លាប់បាត់ហើយ គាត់ចាស់ហើយ ។

វណ្ណៈ : ឈ្មោះ?

សារ៉េន : ខ្ញុំអត់ស្គាល់នាមត្រកូលគាត់ទេ គាត់ឈ្មោះ អ៊ឹភួង ។

វណ្ណៈ : ភួង?

សារ៉េន : ចា៎! អ៊ឹភួង ។

វណ្ណៈ : គាត់មិនមែនគេចាប់គាត់យកទៅទេ គាត់ស្លាប់ដោយជរា?

សារ៉េន : អត់ទេ គាត់ដោយជរា ។

វណ្ណៈ : ចុះមីងដូចថាកាលនឹង៧៥នៅកន្លែងមីងធ្វើពេទ្យ កាលមិនទាន់ទៅកោះកុងនឹង ។

សារ៉េន : ពេទ្យភូមិភាគ ។

វណ្ណៈ : ពេទ្យភូមិភាគនឹង គាម៉ុកអីខស្សាហ៍ទៅជួបខាងផ្នែកនឹង?

សារ៉េន : ទៅ ។

វណ្ណៈ : ទៅដែរ?

សារ៉េន : ចា៎! កូនគាត់ធ្វើពេទ្យជាមួយខ្ញុំដែរ ។

វណ្ណៈ : កូនគាត់ឈ្មោះអី?

សារ៉េន : ឈ្មោះ ហ៊ាញ ។

វណ្ណៈ : កូនតាម៉ុក?

សារ៉េន : កូនតាម៉ុក កូនបង្កើតគាត់នឹង ចា៎!ឈ្មោះ ហ៊ាញ ។

វណ្ណៈ : ចឹងកូនតាម៉ុកធ្វើពេទ្យជាមួយមីងដែរ?

សារ៉េន : ចា៎! ធ្វើពេទ្យ ។

វណ្ណៈ : ឈ្មោះអី ហ៊ាញទៅ?

សារ៉េន : ភ្លេច ព្រាក ហ៊ាច ដឹងថាកូនតាម៉ុក..... ព្រាក ហ៊ាញ ។

វណ្ណៈ : ហ៊ាញ?

សារ៉េន : ចា៎! ព្រាក ហ៊ាញ ។

វណ្ណៈ : នឹងកូនតាម៉ុកហើយ?

សារ៉េន : កូនគាត់ ។

វណ្ណៈ : ចឹងកូនតាម៉ុក ហ៊ាញនឹង ស្រី ឬប្រុស?

សារ៉េន : ស្រី ។

វណ្ណៈ : អត់បានធ្វើធំ កូនស្រីអត់មានកាន់តំណែងប្រធានពេទ្យអីទេ?

សារ៉េន : អត់ៗទេ ។

វណ្ណៈ : អត់ទេ?

សារ៉េន : ចា៎! កូនគាត់.........(ស្តាប់មិនបាន) ។

វណ្ណៈ : ស្គាល់យាយកេនទេ?

សារ៉េន : អត់ ខ្ញុំអត់ស្គាល់ ។

វណ្ណៈ : អត់ស្គាល់ទេនេះ?

សារ៉េន : ចា៎!

វណ្ណៈ : យាយកេននឹងគាត់ត្រូវប្អូនតាម៉ុកដែរ ហើយយាយកេននឹងគាត់ប្រធានពេទ្យគិរីវង់អីដែរកាលនឹង?

សារ៉េន : គាត់នៅគិរីវង់ នៅស្រុកខុសគ្នាឆ្ងាយ ។

វណ្ណៈ : ប៉ុន្តែនៅស្រុកភូមិជាមួយមីង?

សារ៉េន ៖ ចា៎! គ្រញាំងធំ គាត់នៅភូមិតាទាប ។

វណ្ណៈ ៖ ចឹងមីងស្គាល់តាម៉ុក អត់ស្គាល់តាទិត អត់ស្គាល់យាយកេនអីទេ?

សារ៉េន ៖ តាម៉ុក បែបថាភូមិឃុំជាមួយគ្នា ប៉ុនភូមិខុសគ្នាយើងម៉េចស្គាល់ យើងនៅក្មេងៗ ។

វណ្ណៈ ៖ អូ! ដោយសារយើងក្មេង?

សារ៉េន ៖ ចា៎! ជំនាន់នឹង ។

វណ្ណៈ ៖ ចុះមីងនៅពេទ្យកោះកុងនឹង តើកន្លែងពេទ្យមីងនឹង ព្យាបាលប្រជាជន ឬក៏ព្យាបាលរដ្ឋ?

សារ៉េន ៖ មន្ទីរពេទ្យខ្ញុំព្យាបាល.........(ស្តាប់មិនបាន) ។

វណ្ណៈ ៖ ទាំងប្រជាជន ទាំងទ័ពនេះ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចឹងការជំនាន់នឹង ដូចថាមីងមានចិត្តស៊ុំដូចថាចង់មកលេងផ្ទះ ចង់មកអី?

សារ៉េន ៖ ខ្ញុំនឹកផ្ទះមហានឹក ប៉ុនគេអត់ឲ្យមក ។

វណ្ណៈ ៖ អត់ឲ្យមក?

សារ៉េន ៖ ចា៎! ខ្ញុំនឹកមហានឹកហើយ នឹកផ្ទះណាស់ ។

វណ្ណៈ ៖ តែមីងដឹងថាខាងផ្ទះមីងអី ជាមួយឪពុកម្តាយអីអាចផ្ញើសំបុត្រទាក់ទងអីគ្នាបានទេ?

សារ៉េន ៖ អត់ ។

វណ្ណៈ ៖ អត់បានទេ?

សារ៉េន ៖ ចា៎! អត់ទេ អត់ដែលផ្ញើបាន អត់ដឹងដំណឹងទៀត ។

វណ្ណៈ ៖ អត់ដឹងដំណឹងទៀត?

សារ៉េន ៖ ចា៎! ដូចថាលាក់រឿងខ្លួន ខាងក្នុងនោះក៏លាក់ ព្រោះចេះខ្លាច ម៉ែខ្ញុំក៏ខ្លាចខ្លះ ។

វណ្ណៈ ៖ ចឹងពេលមីងទៅធ្វើនៅកោះកុង តាម៉ុកមានមក?

សារ៉េន ៖ .....(ស្តាប់មិនបាន) ។

វណ្ណៈ ៖ កោះកុងនឹង ទ័ពយើងចាំការពារព្រំដែនដែរ?

សារ៉េន ៖ ចា៎! តាមឆ្នេរសមុទ្រ ជាមួយថៃជាមួយអី ។

វណ្ណៈ ៖ តាមឆ្នេរសមុទ្រជាមួយថៃ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ វ៉ៃជាមួយថៃ វ៉ៃជាមួយអី?

សារ៉េន : អត់ដែលរើជាមួយថៃទេ អត់ ។

វណ្ណៈ : ចឹងពេទ្យដូចថាពេទ្យកាលសម័យមីងនៅកង់ទ័ពនឹងមិនមានអ្នករបួសដោយសារគ្រាប់ ដោយ សារអីទេ?

សារ៉េន : អត់ទេ អត់ដែលមាន ។

វណ្ណៈ : ចឹងគ្រាន់ពចឹងគ្រាន់ព្យាបាលជម្ងឺធម្មតា?

សារ៉េន : ចា៎! ជម្ងឺធម្មតាឈឺ គ្រុនចាញ់ ឈឺអីផ្សេងៗចឹងណា ។

វណ្ណៈ : ចុះប្រជាជនវិញឈឺអី ភាគច្រើនគាត់ឈឺអី?

សារ៉េន : ប្រជាជន ភាគច្រើនដូចថាគ្រុនចាញ់ ខ្វះខ្វះជីវជាតិចឹងណា យើងហូបចុកអត់បានគ្រប់ គ្រាន់ ។

វណ្ណៈ : ឈឺហើម ឈឺអី?

សារ៉េន : ឈឺហើម កើតទាចទឹក ជម្ងឺទូទៅគ្រប់ប្រភេទនឹង ។

វណ្ណៈ : តាមពិតទាចទឹកជម្ងឺ ហើមពោះអី ដោយសារយើងអត់មានអីហូបបានជាហើមសាច់ហើម អី?

សារ៉េន : ចា៎! វាបាត់បង់ជីវជាតិ ។

វណ្ណៈ : ចុះជម្ងឺបែបនឹង នៅក្នុងសម័យនឹងអាចព្យាបាលរស់ច្រើន?

សារ៉េន : មិនសូវទេ ព្រោះវាទៅដល់មន្ទីរពេទ្យមានតែឆ្អឹងស្គមកំប្រឹងៗខ្វះអាហារខ្វះជីវជាតិគ្រប់មុខ ចឹង ហើយយើងមិនងាយកែដែរនឹង ព្យាបាលខំបម្រើអស់លទ្ធភាព ប៉ុន្តែធ្វើម៉េចជួយវា មិនបាន ។

វណ្ណៈ : ចុះមីងដល់ពេលទៅពេទ្យ មីងមានរបបអីលួចលាក់ឲ្យអ្នកជម្ងឺហូបដែរ?

សារ៉េន : ឲ្យ ។

វណ្ណៈ : ឲ្យដែរ?

សារ៉េន : ចា៎!

វណ្ណៈ : តាមពិតនៅកន្លែងខ្វះ ខ្ញុំឃើញថាគេស្វែងយល់ ពេលហើមឈឺហើមចឹង ឲ្យបាយទៅជា ស្រក់ក៏មានដែរ មិនបាច់ថ្នាំក៏ជាដែរ ។

សារ៉េន : ចា៎!

វណ្ណៈ : នឹងដោយសារថាខ្វះជាតិអាហារ ។ ចឹងមីងថា មីងដឹងថាពេលនឹងដឹងថាប្រជាជនអត់បាយ អត់អីហូប អត់មានអីហូប មីងដឹងទេ?

សារ៉េន : អត់សូវបានទៅភូមិផង នៅតែ ខ្ញុំនៅកន្លែងវះកាត់ ។

វណ្ណៈ : អត់សូវដឹង ប៉ុន្តែមីងដឹងតាមរយៈប្រជាជនមកព្យាបាល?

សារ៉េន : ដូចថាប្រជាជនមិនសូវហ៊ាននិយាយទេ ដល់អ្នកណាជិតស្និតចឹង បានខ្សឹបប្រាប់ថាប៉ុននឹង ថាអត់មានអីហូបអីចឹង ។ ហើយបើនៅក្នុងមន្ទីរពេទ្យម៉េង អត់ដឹង ។ ហើយស្លាប់រស់ប្រជាជន អ្នកស្គាល់អីទៅសម្រាកពេទ្យគាត់ប្រាប់ថាវេទនា បានដឹង ។

វណ្ណៈ : ចឹងអាហារនឹង បើតាមខ្ញុំ....កើតមានគ្រប់ទីកន្លែងទាំងអស់ ខេត្តណាក៏ខ្វះខាតដែរ ។

សារ៉េន : ជីវភាពនិយាយរួមទូទាំងប្រទេស ។

វណ្ណៈ : បាទ! ទូទាំងប្រទេសមែន ។

សារ៉េន : អត់នែក!មានបាយហូបតែក្រសួងមន្ទីរ ។

វណ្ណៈ : បាទ! អ្នកធ្វើការនៅក្រសួងមន្ទីរគេមានបាយហូប ។

សារ៉េន : ចាំ! មានបាយហូប ហើយបើថាប្រជាពលរដ្ឋនិយាយរួមទូទាំងប្រទេស ពុស្សូរតែអត់គ្រប់តែគ្នា ។

វណ្ណៈ : មីងយល់ទេ មូលហេតុអីបានប្រជាជនមានការខ្វះខាតអីចឹង តើមីងមានឆ្ងល់ទេ?

សារ៉េន : អត់ ការមុនអត់ដឹងរឿងឆ្ងល់ ដល់រត់មកបានដឹងៗ ។

វណ្ណៈ : ចុះមីងដូចថាការខ្វះខាតអីចឹង មីងថាថ្នាក់ក្រោមធ្វើឲ្យខ្វះខាត ឬក៏មីងគិតថាអានេះជាបញ្ជាមកពីលើ ឬយ៉ាងម៉េច ចិត្តរបស់មីងគិត?

សារ៉េន : ចិត្តរបស់ខ្ញុំ ខ្ញុំថាបើខាងលើចំម៉ងមិនដល់ប៉ុននឹងទេ ប៉ុនអាចស្ពានកណ្ដាលៗហើយសម្លាប់ច្រើនក៏ស្ពានកណ្ដាលដែរ ។

វណ្ណៈ : ចឹងអាថ្នាក់ក្រោមថ្នាក់អីនឹង អ្នកបង្អត់បាយ បង្អត់អីដឹង?

សារ៉េន : អ្នក ហឺ! កាលជំនាន់នឹង ត្រឹមប្រធានក្រុមក៏មានអំណាចដែរ ប្រធានក្រុមប្រធានអីគេនឹងមានអំណាចហើយ ។

វណ្ណៈ : ចុះហេតុអីបានថ្នាក់លើអត់ដឹងអត់ពុអីដែលគេធ្វើចឹង?

សារ៉េន : មិនដឹងម៉េចខ្ញុំអត់យល់ដែរនឹង ខ្ញុំអត់សូវយល់ដែរ ។

វណ្ណៈ : ចុះមីងកាលជំនាន់មីង គេដែលចាប់គូឲ្យរៀបការជាគូៗ?

សារ៉េន ៖ អូ! នឹងហើយចាប់ ពួកខ្ញុំខ្លះអីអ្នកការ អត់ដឹងខ្លួនដល់ថ្ងៃគេហៅទៅការ ខាងកងទ័ពក៏ចឹង ។

វណ្ណៈ ៖ ចុះមីង?

សារ៉េន ៖ អត់ទេ ខ្ញុំមកការនៅនេះនឹង ខ្ញុំមកការនៅនេះ ការពេញច្បាប់ ។

វណ្ណៈ ៖ ចុះមីងកាលនឹងម៉េចបានអត់បានការនឹងគេ?

សារ៉េន ៖ ខ្ញុំអត់យក ។

វណ្ណៈ ៖ គេចម៉េច គេចបាន?

សារ៉េន ៖ គេចបាន អត់យក ។

វណ្ណៈ ៖ ចុះតែនេះគេហៅទៅ គេភូតយើងថាទៅជប់លៀង ជប់អី?

សារ៉េន ៖ អត់ទេ កាលនឹងខ្ញុំមានបងប្អូនខ្សែខាងពុកខ្ញុំគាត់ធ្វើគណៈតំបន់ ។

វណ្ណៈ ៖ ពីណាគេ?

សារ៉េន ៖ ឈ្មោះ ពូរ៉ត ៗ ប៉ុនស្លាប់អស់ហើយឥឡូវ ។ ហើយដល់ចឹងទៅអត់ទេ បើពេទ្យក្រៅពីខ្ញុំ អាខ្លះកំពុងនៅលេង ស្រាប់ដល់ហា!នារីមុជទឹកមុជអីធ្វើខ្លួនចូលរៀបការ ម៉ាភ្លែតនឹងគេហៅទៅ ។

វណ្ណៈ ៖ ការ៤-១០-២០គូភ្លាមទៅ?

សារ៉េន ៖ ការម្តង៨គូ ១០គូ ជាមួយកងទ័ពនឹង ។

វណ្ណៈ ៖ ចុះមីងថាត្រូវជាឪពុកមា ដែលជាប្រធាន?

សារ៉េន ៖ ធ្វើ គាត់ធ្វើគណៈតំបន់នឹង?

វណ្ណៈ ៖ គណៈតំបន់ ។

សារ៉េន ៖ បងប្អូន ប៉ុនឆ្ងាយហើយ គាត់.... ។

វណ្ណៈ ៖ តំបន់ប៉ុន្មាន តំបន់នឹង?

សារ៉េន ៖ ខេត្តកោះកុង ៗ បើយើងឥឡូវគេហៅថាហ្វាយខេត្ត ពីមុនគាត់ប្រធានតំបន់នឹង ។

វណ្ណៈ ៖ ចឹងគណៈតំបន់នឹង គាត់ឈ្មោះអី?

សារ៉េន ៖ ឈ្មោះ រ៉ន ។

វណ្ណៈ ៖ ឈ្មោះអី រ៉ន?

សារ៉េន ៖ ខ្ញុំភ្លេចនាមត្រកូល មិនចាំ ។

វណ្ណៈ ៖ រ៉ននឹងនៅមកពីតាកែវ?

សារ៉េន ៖ អត់ទេ គាត់នៅខាងត្បូងត្រពាំងអណ្ដើក អឺ! មិនដឹងភូមិអីៗ

វណ្ណៈ ៖ ត្រពាំងអណ្ដើកតាកែវដែរនឹង ខេត្តតាកែវដែរ?

សារ៉េន ៖ គ្មានទៅក្នុងស្រុកឈូកអានឹង ដំណាក់ស្នួលៗគាត់នៅមកពីភូមិដំណាក់ស្នួល នៅក្នុងស្រុកឈូកៗ ខេត្តកំពតៗ

វណ្ណៈ ៖ គាត់មកកាន់រយៈពេលខ្លីឬក៏យ៉ាងម៉េច?

សារ៉េន ៖ ខ្លីៗ

វណ្ណៈ ៖ ចុះមុនវ៉ននឹងពីណាគេ គណៈតំបន់?

សារ៉េន ៖ មុននឹងវត់ចូលថៃអត់ទៅ ពួកខ្ញុំទៅដល់ដឹងអ្នកណាគេ ខ្ញុំអត់ស្គាល់ដែរៗ

វណ្ណៈ ៖ ចឹងអត់ស្គាល់ទេ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចុះគណៈភូមិភាគនៅនឹង ភូមិភាគពីណាកាន់កាប់នៅកោះកុងនឹង?

សារ៉េន ៖ គណៈភូមិភាគៗកោះកុងភូមិភាគនិរតី ក៏ភូមិភាគបស្ចឹមភ្លេចហើយ ភូមិភាគបស្ចឹម តាសើងៗគាត់ភូមិភាគបស្ចឹម ប្រធានភូមិភាគបស្ចឹម ប៉ុនស្លាប់អស់ហើយៗ

វណ្ណៈ ៖ តាស៊ើង?

សារ៉េន ៖ ចា៎! ផ្ទះគាត់នៅត្រពាំងធំដែរៗ

វណ្ណៈ ៖ គាត់ស្លាប់ពេលតាស៊ើង?

សារ៉េន ៖ តាស៊ើងស្លាប់ការវត់៧៩នឹងៗ

វណ្ណៈ ៖ ម៉េចបានគាត់ស្លាប់?

សារ៉េន ៖ តាស៊ើង ដឹងមូលហេតុអីបានស្លាប់នឹង ព្រោះក្រោយមកវត់មក ឮសូរគាត់ស្លាប់ គេនិយាយថាសម្លាប់បាត់ហើយៗ

វណ្ណៈ ៖ គេបាញ់គាត់ គេសម្លាប់គាត់ ឬក៏ម៉េច?

សារ៉េន ៖ គេបាញ់គានឹង គេបាញ់គាត់ ឮសូរថាគេបាញ់ៗ

វណ្ណៈ ៖ មិនដឹងខាងណាបាញ់ទេ?

សារ៉េន ៖ នឹង អត់ដឹងខាងណាបាញ់ វត់ៗ

វណ្ណៈ ៖ គាត់មកពីតាកែវ?

សារ៉េន ៖ អឺ!

វណ្ណៈ : ចឹងគាស៊ើងកាន់រហូតដល់៧៩ដែរ ។ តែមុននឹងពួកនឹងរត់ទៅថៃរត់ទៅអី?

សារ៉េន : កាលមុននែក! គណៈតំបន់ បើយើងឥឡូវហៅចៅហ្វាយខេត្ត ។ គាត់រត់ចូលថៃទាំងអស់ ។

វណ្ណៈ : ចឹងគាត់ដឹងខ្លួនមុន គាមមើល?

សារ៉េន : ចា៎!

វណ្ណៈ : គាមពិតគេត្រូវចាប់ពួក?

សារ៉េន : គេត្រូវចាប់ ។

វណ្ណៈ : ចាប់សេរីមុន?

សារ៉េន : ចា៎!

វណ្ណៈ : ចាប់តែប្រហែលជាគាត់រត់ទៅថៃៗ ទទួលដែល ប្រហែលជាពួកគាត់ចេះថៃដែរក៏មិនដឹង ។

សារ៉េន : ចុះណា ចែវទូកតែម៉ាយប់នឹងដល់ៗខ្វះ ។

វណ្ណៈ : ចែវទូកទៅ ប៉ុន្តែយើងអត់មានសំបុត្រស្នាមទៅ ម៉េចថៃទទួល?

សារ៉េន : ទទួលចូលទៅនៅថៃ ប្រជាជននៅកោះកុងរត់ចូលថៃច្រើនដែរ ។

វណ្ណៈ : ចឹងប្រជាជននៅកោះកុងនឹង ដោយសារលំបាកពេកប្រថុយរត់ចូលថៃ?

សារ៉េន : ចា៎! ចែវទូកទៅថៃ ។

វណ្ណៈ : ចឹងថៃអត់មានបញ្ជូនមកវិញ?

សារ៉េន : អត់ ។

វណ្ណៈ : ចឹងមីងដូចកាលនឹង មីងនៅតែពេទ្យរហូត អត់មានបានចេញទៅណាទៅណែ?

សារ៉េន : អត់ ខ្ញុំនៅធ្វើពេទ្យ ។

វណ្ណៈ : ពេទ្យនឹងមានបុគ្គលិកប៉ុន្មាននាក់?

សារ៉េន : ពេទ្យកន្លែងខ្ញុំនឹង?

វណ្ណៈ : កន្លែងមីងនឹង ។

សារ៉េន : ពេទ្យកន្លែងខ្ញុំតែម្តង៣០០ជាង ។

វណ្ណៈ : ច្រើនម៉េច?

សារ៉េន : ចា៎! ៣០០ជាង ចុះនៅម៉ាមន្ទីរពេទ្យនឹង វាមានខាងផ្នែកទូទៅ ផ្នែករបួស ផ្នែកធ្វើថ្នាំចាក់ មាន៣ផ្នែក ។

វណ្ណៈ : ៣០០នាក់នឹងមកពីណា?

សារ៉េន : គ្រប់ខេត្ត ដឹងខេត្តណាខ្លះ ច្រើនណាស់ ។

វណ្ណៈ : ចឹងដូចនៅក្នុងមន្ទីរពេទ្យនឹង ដូចកន្លែងមីងរស់នៅមានដូចថា បាត់ខ្លួនឲ្យគេចាប់គេអីមានដែរ?

សារ៉េន : មាន ។

វណ្ណៈ : មានដែរ?

សារ៉េន : មាន ។

វណ្ណៈ : គេចាប់ដោយសារមូលហេតុអី មីងដឹងទេ?

សារ៉េន : គេ មកចាប់យប់ ចាប់ប្រធានពេទ្យ ប្រធានមុនអ៊ីភួងនឹងគាត់ឡើង ឈ្មោះពូសឹង១ នឹងគាត់ដុកទ័រវ៉ះគាត់ គេមកចាប់ ។ ចាប់យប់ដឹងមូលហេតុអី បើអត់ដឹងដែរ គេមកចាប់ ។

វណ្ណៈ : ចាប់ខ្លួនបាត់ច្រើន?

សារ៉េន : ច្រើន ។

វណ្ណៈ : ប្រហែលជាប៉ុន្មានដែរ?

សារ៉េន : បុគ្គលិកនឹង អ្នកមេ១ អ្នកបេះ១នឹងបទពិសោធន៍ផ្ទាល់ អ្នកបេះ១ ។

វណ្ណៈ : ប្រធានពេទ្យឈ្មោះអីគេ?

សារ៉េន : ពូសឹង១គាត់វ៉ះគាត់តាំងសង្គ្រាម៥ឆ្នាំមក ហើយដល់ពេលយើងសម័យ៣ឆ្នាំក៏គាត់នៅវ៉ះកាត់រហូត គាត់ស្មាត់ ប៉ុន្តែដល់ហើយគេយកគាត់ទៅសម្លាប់ចោល ។

វណ្ណៈ : គេចាប់គាត់មកភ្នំពេញវិញ ឬក៏ចាប់?

សារ៉េន : អត់ទេ គេចាប់យកទៅសម្លាប់នៅកោះកុងម៉ង ។

វណ្ណៈ : ម៉េចមីងចឹង?

សារ៉េន : បើដឹងអី បើគេមកយកយប់ ។

វណ្ណៈ : មកយកយប់?

សារ៉េន : ចា៎! មកយកយប់ ។

វណ្ណៈ : ចុះមីងជាកូនចៅ មីងភ័យទេ ពេលដែលគេមកចាប់?

សារ៉េន : ភ័យ១ខ្លាច ។

វណ្ណៈ : ភ័យខ្លាចគេចាប់ដោយដែរ?

សារ៉េន : ខ្លាចគេឆ្លើយដាក់យើងដាក់អីចេះតែភ័យ ។

វណ្ណៈ : ចឹងសូម្បីតែខ្មែរក្រហមគ្នាឯង បម្រើឲ្យខ្មែរក្រហមគ្នាឯងហើយ?

សារ៉េន : ក៏ភ័យដែរ ។

វណ្ណៈ : នៅមានភ័យដែរ?

សារ៉េន : ចា៎!

វណ្ណៈ : ចឹងខ្លាចគេចាប់យើងដែរ?

សារ៉េន : ចា៎! ខ្លាច ។

វណ្ណៈ : ចឹងមិនមែនថាតែប្រជាជនស្លាប់ទេ អ្នកធ្វើការស្លាប់ដែរ?

សារ៉េន : ស្លាប់ ខ្លាចទាំងអស់គ្នានឹង ។

វណ្ណៈ : ចឹងកាលនៅកោះកុងនឹងដូចថាទាហានជើងទឹកជើងអីមានច្រើនដែរ?

សារ៉េន : មានច្រើន ។

វណ្ណៈ : ប៉ុន្តែអត់មានព្យាបាលដោយសារត្រូវគ្រាប់ត្រូវអីទេ?

សារ៉េន : អត់ទេ អត់មានទេ គ្រាន់រំដោះ៧៥ហើយ គឺចប់សង្គ្រាម មកដល់៧៩រត់នៅកោះកុង ។

វណ្ណៈ : ចឹងមីងដូចថាមីងធ្វើរយៈពេល៣ឆ្នាំជាងនៅកោះកុងនឹង តើមីងឃើញប្រជាជនស្លាប់នៅមន្ទីរពេទ្យច្រើន?

សារ៉េន : ច្រើន ស្លាប់ច្រើន ។

វណ្ណៈ : ប្រហែលប៉ុន្មានរយនាក់ ប៉ុន្មានពាន់នាក់ទៅ?

សារ៉េន : កន្លែងកប់សពអ្នកស្លាប់ដែលនៅមន្ទីរពេទ្យនឹង គេហៅឃុំអូរម្កាក់នឹងច្រើនណាស់ សពស្លាប់ ប៉ុនដឹងប៉ុន្មានរយ បើទៅកប់រាល់ថ្ងៃ ។

វណ្ណៈ : ម៉ាថ្ងៃស្លាប់ប៉ុន្មាន?

សារ៉េន : ម៉ាថ្ងៃដួនណា២-៣ចឹងទៅ ស្លាប់ ។

វណ្ណៈ : ស្លាប់ចឹងគេអត់ហៅបងប្អូនមកយកទេ?

សារ៉េន : អត់ទេ ពេទ្យយកទៅ ។

វណ្ណៈ : ពេទ្យយកទៅកប់ចោលតែម៉ង?

សារ៉េន : ចា៎! យកទៅកប់ ។

វណ្ណៈ : ចឹងអត់មានសាច់ញាតិណាដឹងដំណឹងអី?

សារ៉េន ៖ អត់ដឹង កាលនឹងដូចថាប្រជាជនមិនដែលបានចូលមន្ទីរពេទ្យផង ចូលមកតែអ្នកឈឺនឹង ។

វណ្ណៈ ៖ អ្នកដែលយើងអត់ឈឺអីគេមិនឲ្យចូល?

សារ៉េន ៖ ចា៎! អត់មានដែលចូលផង ។

វណ្ណៈ ៖ ចុះស្លាប់ដោយសារខ្វះជាតិអាហារ?

សារ៉េន ៖ ចា៎! គ្រប់គ្នាដោយសារខ្វះជីវជាតិ ។

វណ្ណៈ ៖ ចុះថ្នាំៗសម្រាប់ព្យាបាលនឹងមកពីខាងណាខ្លះ?

សារ៉េន ៖ ថ្នាំនៅកន្លែងខ្ញុំ?

វណ្ណៈ ៖ បាទ!

សារ៉េន ៖ ឃើញគេដឹកមកពីភ្នំពេញមក ថ្នាំសុទ្ធមកពីថ្នាំចាក់ ថ្នាំអំពូលថ្នាំអី ។

វណ្ណៈ ៖ ចឹងភាគច្រើនថ្នាំអាចម៍ទន្សាយដែរ ឬអត់ទេ?

សារ៉េន ៖ អត់ទេ ។

វណ្ណៈ ៖ អត់មាន?

សារ៉េន ៖ ចា៎! ថ្នាំព្យាបាលថ្នាំពេទ្យយើងម៉ង ។

វណ្ណៈ ៖ ល្អៗ?

សារ៉េន ៖ ចា៎!បានជំនួយមកពីចិនក៏មិនដឹង ពីណាក៏មិនដឹង ឡានដឹកចូល ។ ព្យាបាលថ្នាំអាចម៍ទន្សាយ មានតែតាមឃុំតាមភូមិ អាសូរមន្ទីរពេទ្យធំៗអត់ទេ ។

វណ្ណៈ ៖ ចឹងមីងគិតមើលអ្នកដែលបានចូលពេទ្យនឹង ទាល់តែអ្នកនឹងមានមុខមាត់គ្រាន់បើដែរ ឬក៏ប្រជាជនសាមញ្ញចូលពេទ្យបានដែរ?

សារ៉េន ៖ ខ្ញុំប្រជាជន ហើយគេហៅមកឲ្យចូលមកពេទ្យនឹងម៉ង កូនប្រជាជនសុទ្ធសាធ ។

វណ្ណៈ ៖ ចង់និយាយអ្នកជម្ងឺៗឈឺៗ ដូចថាប្រជាជនធម្មតាចូលបានដែរ ឬក៏ទាល់តែជាប់សាច់ញាតិ កម្មាភិបាលបានចូលទៅព្យាបាល?

សារ៉េន ៖ អត់ទេ ប្រជាជនមកបាន អត់មានជាប់បងប្អូនកម្មាភិបាលអីអត់ទេ ។

វណ្ណៈ ៖ ឲ្យតែឈឺគេរុញមក?

សារ៉េន ៖ ឈឺមកកន្លែងពេទ្យឃុំៗបញ្ជូនមកនេះ ។

វណ្ណៈ ៖ ចុះដែលថាចូលមកដល់ពេទ្យ ហើយភាគច្រើនបានចេញទៅវិញដែរ ឬក៏មិនសូវបានចេញទៅវិញទេ?

សារ៉េន ៖ បានចេញច្រើនដែរនឹង ។

វណ្ណៈ ៖ ចេញច្រើនដែរ?

សារ៉េន ៖ ចេញច្រើនដែរ ។

វណ្ណៈ ៖ ដាល្មមៗចេញទៅវិញ?

សារ៉េន ៖ ចាំ!

វណ្ណៈ ៖ លុះត្រាតែអ្នកឈឺធ្ងន់ ហើមជ្រុលអីមិនឯាយទេ?

សារ៉េន ៖ ចាំ! យើងពិបាកព្យាបាលដែរ ពិបាកសង្គ្រោះណាស់ ។

វណ្ណៈ ៖ ចឹងមីងនៅក្នុងរយៈពេលជាង៣ឆ្នាំនឹងមិនបានទៅលេងស្រុកកំណើត ទៅលេងអីទេនេះ?

សារ៉េន ៖ អត់ ។

វណ្ណៈ ៖ ហើយបើយើងនឹកក៏នឹកទៅ?

សារ៉េន ៖ នឹកក៏ ប៉ុនអត់ដែលបានទៅលេង ។ ខ្ញុំទើបបានទៅលេងពេលផ្តាច់ខ្លួនហើយនឹង តាំងពីចេញ ពីផ្ទះមក ទើបបានទៅលេងការផ្តាច់ខ្លួនតាំងពី៩៦ផ្តាច់ខ្លួន ៩៦ ៩៧ ។

វណ្ណៈ ៖ ចុះមីងឮថាពេល៧៩ពេលវៀតណាមចូលមកដល់ ម៉េចបានមីងមិនរត់មកស្រុកកំណើត?

សារ៉េន ៖ មិនដឹងទៅផ្លូវណា អត់ដឹង នៅកោះកុងស្ទុសមុទ្រមិនដឹងទៅផ្លូវណា បើគេនាំទៅណា នាំ មកនឹងហើយ ។ គេនាំមកលិចទៅលិចរហូតមក ចូលថៃប៉ុក ។

វណ្ណៈ ៖ ចុះអ្នកមកពីតាកែវជាមួយមីងច្រើនគ្នាទេ ទៅធ្វើនៅកោះកុងនឹង?

សារ៉េន ៖ អត់ទេ ពីតាកែវតែខ្ញុំម្នាក់ឯង ។

វណ្ណៈ ៖ ចឹងចង់ទៅក៏ទៅមិនកើតដែរនោះ?

សារ៉េន ៖ ចាំ!

វណ្ណៈ ៖ ៧៩មីងរត់ចេញពីកោះកុង?

សារ៉េន ៖ ចេញពីកោះកុង ។

វណ្ណៈ ៖ រត់ទៅខាងណា?

សារ៉េន ៖ រត់មកលិខរហូតចូលក្នុងយ៉ៃៗថៃ ។

វណ្ណៈ ៖ រត់ចូលដីថៃ?

សារ៉េន ៖ ចាំ!

វណ្ណៈ ៖ ចូលដីថៃៗវាធ្វើម៉េចដែរ?

សារ៉េន : អត់មានធ្វើអីផង ចាំមើលខ្ញុំរត់ចូលបានប្រហែលម៉ាម៉ោងឃើញយន្តហោះ អ៊ំខៀវ សំផន ជិះកន្ទុំរុយនឹង ចុះនៅកន្លែងប្រជាជនរត់ចូលនឹង ។

វណ្ណៈ : ចឹង?

សារ៉េន : ចា៎! នៅក្នុងព្រៃនឹង ។

វណ្ណៈ : ម៉េចដឹងយន្តហោះខៀវ សំផន?

សារ៉េន : ចុះគាត់ចុះមកជួប ប្រជាជននៅនឹង ដូចថាយើងនៅចឹង យន្តហោះចុះចឹង ប្រជាជនមករោមណា អ៊ំខៀវ សំផន គាត់ចុះមកចេញមក ។

វណ្ណៈ : ខៀវ សំផន ពីណាទៀត?

សារ៉េន : ឃើញតែអ៊ំខៀវ សំផន ហើយប៉ុន្មាននាក់២-៣នាក់ទៀត អត់ស្គាល់ផង ។

វណ្ណៈ : ហើយគាត់ចុះមក គាត់ថាម៉េច?

សារ៉េន : គាត់ថាឲ្យកុំភ័យ ស្អែកនឹងឲ្យថៃទៅដឹកដាក់នៅខ្មែរ កំរៀង ខ្មែរយើងនឹង ។ ដល់ស្អែកឡើងឡានថៃអាធំៗដឹកមកដាក់នៅខ្មែរ ។

វណ្ណៈ : ចឹងខៀវសំផន ប្រាប់ថាឲ្យមកខ្មែរ ចឹងឡានដឹកមកខ្មែរទៅ?

សារ៉េន : ចា៎! ឡានថៃដឹក ។

វណ្ណៈ : ចឹងមីងនៅខ្មែរៗរយៈពេលប៉ុន្មានទៀត?

សារ៉េន : នៅខ្មែរប្រហែលម៉ាឆ្នាំ បានផ្លាស់មកនៅខេត្តចក្រី ។

វណ្ណៈ : ចក្រី?

សារ៉េន : ចា៎!

វណ្ណៈ : មីងមកចក្រី មីងរៀបការនៅ?

សារ៉េន : នៅទេ នៅពេទ្យរហូត ។

វណ្ណៈ : ចឹងមីងនៅក្នុងសម័យតស៊ូក្រោយ៧៩ដដែល មីងធ្វើពេទ្យដដែលឬក៏កងដឹកជញ្ជូន?

សារ៉េន : អត់ទេ ខ្ញុំនៅពេទ្យរហូត ។

វណ្ណៈ : ពេទ្យទៀត?

សារ៉េន : ចា៎! ខ្ញុំនៅកន្លែងវះកាត់ ។

វណ្ណៈ : ចុះមីងចេះវះកាត់?

សារ៉េន : ចេះតិចៗ ។

វណ្ណៈ :	ចេះដែរ?

សារ៉េន :	មិនសូវពឹងគេ ធ្វើបានខ្លះ ។

វណ្ណៈ :	ចុះមិនដឹងបូង ឧបមាថាគេត្រូវរបួស ដាច់ជើងដាច់អី ហ៊ានវះកាត់ដែរ?

សារ៉េន :	......(ស្តាប់មិនបាន)..........។ ខ្ញុំជ្រាបលោកពូតាមត្រង់ចុះ ឥឡូវអាយុ៥៦ ខ្ញុំឈប់អាយុ៤៩ ខ្ញុំឈប់កាត់សក់ខ្វី ហូបស្លាម្ល ដាំម្លូកើតហូបទើបឈប់ធ្វើពេទ្យ ខ្ញុំនៅកន្លែងវះកាត់របួត តាំងពីអាយុ២០របួតដល់អាយុ៤៩ ប្រឡូកក្នុងសង្គ្រាមរបួត ប៉ុនអត់ដែលសម្លាប់អ្នកណា មានសង្គ្រោះ ។

វណ្ណៈ :	អានេះយើងនិយាយការពិត?

សារ៉េន :	ចា៎!

វណ្ណៈ :	ចឹងអាចេះវិជ្ជាវះកាត់នឹង មីងពីណា ពេទ្យចិនបង្រៀនម៉េចដែរ?

សារ៉េន :	រៀនជាមួយដុកទ័រចិនផង រៀនជាមួយវេជ្ជបណ្ឌិតជួន ជឿន ។

វណ្ណៈ :	មីងស្គាល់ដែរ?

សារ៉េន :	ចា៎! ព្រោះគាត់គ្រូខ្ញុំ បង្រៀន ។

វណ្ណៈ :	វះកាត់ល្បី?

សារ៉េន :	ចា៎!

វណ្ណៈ :	ចិន និង?

សារ៉េន :	វេជ្ជបណ្ឌិតជួន ជឿន ។

វណ្ណៈ :	គាត់ឈ្មោះ ជួន ជឿន?

សារ៉េន :	ជួន ជឿន ។

វណ្ណៈ :	លោកតាជួន ជឿន សព្វថ្ងៃគាត់ស្លាប់ហើយ?

សារ៉េន :	គាត់នៅភ្នំពេញ ។

វណ្ណៈ :	សព្វថ្ងៃគាត់នៅភ្នំពេញ?

សារ៉េន :	ចា៎! ចាស់ហើយឥឡូវ ។

វណ្ណៈ :	លោកតាជួន ជឿន គាត់កាចទេ?

សារ៉េន :	ស្លូត ។

វណ្ណៈ :	ស្លូតទេនេះ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ឃើញគាត់វះកាត់កាលសម័យនឹងល្បី?

សារ៉េន ៖ ល្បីណាស់ ។

វណ្ណៈ ៖ តែក្រោយមក គាត់អត់ធ្វើពេទ្យធ្វើអីទៀត?

សារ៉េន ៖ គាត់ចាស់ហើយ គាត់ញ៉័រ ។

វណ្ណៈ ៖ ពេល៧៩ហើយគាត់ចាស់ដែរ ។ គាត់អាយុប្រហែលប៉ុន្មានឥឡូវ?

សារ៉េន ៖ មិនដឹងប៉ុន្មានទេ គាត់ ៧៩ដែលគាត់ធ្វើដល់ឆ្នាំប៉ុន្មានទេវះកាត់៩៥ ៩៦ មុនផ្ដាច់ខ្លួនគាត់ឈប់ ។

វណ្ណៈ ៖ គាត់ឈប់?

សារ៉េន ៖ គាត់ចាស់ ។

វណ្ណៈ ៖ ៩៦ផ្ដាច់ខ្លួន គាត់ឈប់រវល់ជាមួយនយោបាយ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ធ្វើពេទ្យធ្វើអី?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ធ្វើទៀត អាចល្បីទៀតតាមមើល?

សារ៉េន ៖ ធ្វើពេទ្យមិនមានអ៊ីខ្វាយខ្វល់ សង្គ្រោះមនុស្សៗ ។

វណ្ណៈ ៖ ចឹងមីងនៅជាមួយតាដួន ជឿន រយៈពេលយូរដែរ?

សារ៉េន ៖ គាត់មកបង្រៀនទេ នៅមន្ទីរពេទ្យខ្ញុំ......(ស្ដាប់មិនបាន) .....គាត់ដុកទ័រវះកាត់ វះយកកូនកាត់ថ្លើម តពោះវៀន ធ្លាយក្រពះអី គាត់យកពោះវៀនធំមកតជាប់ជាមួយក្រពះអីគាត់បេះទាំងអស់ ។

វណ្ណៈ ៖ ពីណាគេ?

សារ៉េន ៖ ពូវឿន ប៉ុនគាត់ស្លាប់ហើយ ផ្ទុះមីនគោន ជិះឡានផ្ទុះមីនគោន ។

វណ្ណៈ ៖ ចុះមីងហ៊ានវះកាត់តពោះវៀន តអី?

សារ៉េន ៖ អត់ទេ គ្រាន់ជំនួយការទី១ចឹងទៅ ។

វណ្ណៈ ៖ តែត្រឹមកាត់ជើងកាត់អី មីងកាត់បាន?

សារ៉េន ៖ ធ្វើបាន ។

វណ្ណៈ : ភ្នែកអី?

សារ៉េន : ធ្វើបាន ភ្នែកអីមាននារី២នាក់ ត្រឹមវេះភ្នែកវេះអី តែពួកខ្ញុំធ្វើទេ តែនារីៗនឹង ។

វណ្ណៈ : ប៉ុន្តែយើងអាពេលធ្វើភ្នែកធ្វើអី សុទ្ធតែចាក់ថ្នាំសន្លប់?

សារ៉េន : ចាក់ថ្នាំសន្តំ ចុះ................(ស្តាប់មិនបាន) ។

វណ្ណៈ : ស្ពឹកនៅឈឺដែរ?

សារ៉េន : ស្ពឹក អត់ទេតែពេលចាក់ស្ពឹកអត់ឈឺទេ កន្លែងខ្ញុំធ្វើនឹង ។ ប៉ុនចាក់ថ្នាំស្ពឹកវាមិនសូវខូចខួរក្បាល បើចាក់ថ្នាំសន្លប់វាខូចខួរក្បាល ។

វណ្ណៈ : ចុះមីងដល់ពេលនៅខ្មែមៗរយៈពេលប៉ុន្មាន បានមីនទៅចល័តខាងណាខាងណែទៀត?

សារ៉េន : នៅខ្មែមបានម៉ាឆ្នាំ បានផ្លាស់ពីខ្មែមមកនៅចក្រី ។

វណ្ណៈ : ចុះនៅពេទ្យ នៅសម័យនឹង កាលនឹងជិនាញពីណាកាន់កាប់ប្រធានកងពល?

សារ៉េន : តាកន ។

វណ្ណៈ : ចុះតាហុង?

សារ៉េន : តាហុងខាងម៉ាខ្មែ ។

វណ្ណៈ : តាកន ស្អឹកន គាត់?

សារ៉េន : នែក! ម៉េចទេ ហៅគាត់ដឹងម៉េច តាកន ដឹងថាប្រធានរួម ពេទ្យខ្ញុំ ប្រកមន្ទីរពេទ្យ២៥០ ប៉ែកខាងលិចនឹងម៉ាចំហៀង ។

វណ្ណៈ : ២៥០នឹងស្អីគេ ហៅតំបន់២៥០ ឬក៏ម៉េច?

សារ៉េន : តំបន់២៥០នឹង គឺតាកន គាត់គ្រប់គ្រង ហើយមានមន្ទីរពេទ្យធំជាងគេនៅកន្លែងខ្ញុំ ពួកមកខាងណាក៏មកនឹងដែរ ។

វណ្ណៈ : ចុះតាបន្ទាប់ពីតាកន មានពីណាពីណែទៀតទេ?

សារ៉េន : បន្ទាប់ពីតាកន អត់ដឹងផង ខ្ញុំដឹងថាតាកន តាសុន សេននឹង គាត់....(ស្តាប់មិនបាន) ។

វណ្ណៈ : ចុះតាសុខ គង់ គាត់មិនមែននៅខាងនេះ?

សារ៉េន : អត់ទេ ។ នៅក្នុងនឹងដែរ ប៉ុន្តែគាត់មិនមែនបានធ្វើធំចឹងទេ ។

វណ្ណៈ : ចុះតាសុខភាព?

សារ៉េន : ពូភាព នៅខាងម៉ាខ្មែ ។

វណ្ណៈ : តាសូ ហុង?

សារ៉េន ៖ ពូហុងនៅម៉ាឡៃដែរ បើតាឈាននៅខាងប៉ៃលិន ។

វណ្ណៈ ៖ ចឹងតាកននៅម្ដុំនេះ?

សារ៉េន ៖ ចាំ!

វណ្ណៈ ៖ ហើយកាលនឹងមីង កាលមីងនៅពេទ្យក្នុងព្រៃនឹង ពេលវ៉ៃជាមួយយួនអីនោះ តើទាហានខ្មែរក្រហមរបួសច្រើនទេ?

សារ៉េន ៖ ច្រើន ។

វណ្ណៈ ៖ ច្រើនដែរ?

សារ៉េន ៖ ចាំ!

វណ្ណៈ ៖ ដឹងស្លាប់ដឹងអីច្រើនដែរ?

សារ៉េន ៖ ស្លាប់ក៏ច្រើនដែរ ។

វណ្ណៈ ៖ ភាគច្រើនស្លាប់ដោយសារសគ្រាម ឬក៏ស្លាប់ដោយសារចាញ់?

សារ៉េន ៖ អត់ចាញ់ទេ ស្លាប់ត្រូវគ្រាប់ម៉ំង បាញ់ត្រូវមករបួសមកម៉ំង ហើយបំពុលថ្នាំ ។

វណ្ណៈ ៖ ហាំ! ម៉េចបានពុលថ្នាំ?

សារ៉េន ៖ ពុលចុះទាហានខាងក្នុងមិបាញ់ផ្សែងពុលមក ហើយទាហានខ្មែរក្រហមមិនចូលទៅ ហើយមិនពុល ។

វណ្ណៈ ៖ ចុះកាលនឹងគេប្រើគីមីដែរ?

សារ៉េន ៖ ចាំ! បាញ់ ៗ ពួកខ្ញុំនៅកន្លែងវ៉ះកាត់នេះវេទនាណាស់ ពួកខ្ញុំនៅកន្លែងវ៉ះកាត់បើអត់បេះតស៊ូនៅអត់បានរបួស ៗ បើចូលម្ដង៥-៦ថ្ងៃធូន់ ៗ បើថាធ្វើពីព្រលឹមចឹងទៅទល់ស្អែកឡើងដូរគ្រាន់ថាយកមួយចេញចឹង មួយចូល ចេញចូល គ្មានបានសម្រាកទេ ហើយហូបត្រីខ គ្មានអីហូប មានញាំល្ហុងជាមួយត្រីខ ហើយទៅដល់កន្លែងណា គឺជីកដីទម្លាក់មុងវ៉ះហើយកន្លែងនឹង ចុះការពារគ្រាប់ភ្លោង ៗ បើមិនចឹងគ្រោះថ្នាក់វ៉ះកាត់ ៗ តែពេទ្យវ៉ះកាត់នឹងជីករណ្ដៅ ។

វណ្ណៈ ៖ ចឹងកន្លែងពេទ្យវ៉ះកាត់នឹង អត់មានធ្វើផ្ទះធ្វើអីចឹងដែរ?

សារ៉េន ៖ អត់ទេ អត់មានធ្វើផ្ទះទេ បើយើងនៅកន្លែងស្រួលដូចថានៅកន្លែងធម្មតាវាមានមន្ទីរវ៉ះកាត់ កន្លែងវ៉ះកាត់ ៗ ដល់ពេលវ៉ៃគ្នាហើយអត់ទេ ទម្លាក់តែមុង ជីកដីហើយទម្លាក់មុងដាក់តុកវ៉ះកាត់ ចំហ៊ុយសម្ភារៈវ៉ះយកនឹងម៉ំង បានទាន់សភាពការណ៍ ។

វណ្ណៈ : ចិនជីកដីធ្វើកន្លែងជាមន្ទីរពេទ្យ?

សារ៉េន : ដាក់តែកន្លែងផ្ទះវះមួយនឹង ចា៎! ដាក់កន្លែង បើមិនចឹងខាងវះកាត់ម៉េចវះបាន២០ថ្ងាយដែរ ដល់ដីក ។

វណ្ណៈ : ចឹងដូចថាបើសិនជាខែវស្សាពិបាកទៀតហើយ ដូចថាគ្មានសម្ភារៈគ្រប់គ្រាន់ អ្នករបួស អ្នកអីចឹង អាចត្រូវភ្លៀងត្រូវអី ដួនស្លាប់?

សារ៉េន : អត់អីទេ ដូចថាយើងប្រក់សង្ក័សីទៅ ដាក់ជីករណ្ដៅចឹងហើយ យើងប្រក់សង្ក័សីខ្ពស់ហើយយើងធ្វើប្រឡាយជុំវិញហូរចេញទៅ យើងបិទឡជិត ហើយយើងដាក់ភ្លើង ។

វណ្ណៈ : ចុះមានអគ្គីសនីមានអី?

សារ៉េន : អគ្គីសនីអី កាកាណូរវ៉ៃ ។

វណ្ណៈ : រវ៉ៃ?

សារ៉េន : កាកាណូរៗវ៉ៃហើយវះ កាកាណូយើង ។

វណ្ណៈ : យើងរវ៉ៃយកភ្លើងទៅ?

សារ៉េន : ចា៎! យកភ្លើង ។

វណ្ណៈ : វះកាត់ទៅ?

សារ៉េន : ចា៎!

វណ្ណៈ : វេទនាដែរ?

សារ៉េន : ហេ៎! ពិបាកណាស់ ពិបាកមែនទែន ។

វណ្ណៈ : ហើយពេទ្យគ្នាច្រើនទេកាលនឹង?

សារ៉េន : ពេទ្យ បុគ្គលិកច្រើនដែលនឹង ប៉ុន្ដែផ្នែកវះកាត់មានតែ៨នាក់ ។

វណ្ណៈ : គាជួន ជឿន គាត់នៅនឹងដែរ?

សារ៉េន : ចា៎! គាត់មកម្ដងៗ គាត់នៅជាប់មន្ទីរពេទ្យគាត់នោះ ។

វណ្ណៈ : មានមន្ទីរពេទ្យធំផ្សេងទៀត?

សារ៉េន : ធំផ្សេង ។

វណ្ណៈ : នៅខាងណាវិញ?

សារ៉េន : ខាងជ-២៥ ៗចូលទៅខាងថៃ ។

វណ្ណៈ : ក្នុងព្រៃនឹង?

សារ៉េន ៖ អត់ទេ នៅថៃនោះ របួសធ្ងន់គេយកទៅថៃ តាជួន ជឿន ។

វណ្ណៈ ៖ ចុះមានមន្ទីរពេទ្យ?

សារ៉េន ៖ ធំ កន្លែងតាជួន ជឿន ដ-២៥ ។

វណ្ណៈ ៖ នៅថៃ ដ-២៥?

សារ៉េន ៖ ចាំ! ដ-២៥ ។

វណ្ណៈ ៖ តាជួន ជឿន គាត់នៅនឹង?

សារ៉េន ៖ គាត់នៅនឹង គាត់នៅកន្លែងមន្ទីរគាត់នឹង ។

វណ្ណៈ ៖ មកព្រៃម្តងម្កាល?

សារ៉េន ៖ ចាំ!

វណ្ណៈ ៖ ចុះមីងដល់ពេលមីងនៅនឹងក្នុងព្រៃនឹងបានប៉ុន្មានឆ្នាំទៅ បានមីងរៀបការរៀបអី?

សារ៉េន ៖ ខ្ញុំទើបយកគ្រួសារផ្តាច់ខ្លួនហើយនឹង ។

វណ្ណៈ ៖ អូ! ចឹងបានមីងទើបមានកូនមួយ?

សារ៉េន ៖ ចាំ! ផ្តាច់ខ្លួនហើយ ។

វណ្ណៈ ៖ បាទ! ចឹងការត្រឹមត្រូវ?

សារ៉េន ៖ ការត្រឹមត្រូវម៉ង ។

វណ្ណៈ ៖ មានភ្លេង មាន?

សារ៉េន ៖ ចាំ! មានភ្លេង មានអ័រកេសអីម៉ង ផ្តាច់ខ្លួនហើយនឹងៗយកម៉ែខាងនោះ ខាងកោះមក ខ្ញុំយកម៉ែពីតាកែវមក ឲ្យគេទៅយកឲ្យ យកមកការ ។

វណ្ណៈ ៖ ចឹងមីងការអាយុច្រើនហើយ?

សារ៉េន ៖ អាយុច្រើនដែរ ខ្ញុំ៤០ ខ្ញុំការអាយុ៤០ ។

វណ្ណៈ ៖ ការអាយុ៤០ហើយ ។ មីងជាប់រវល់តស៊ូរហូត អត់បានពេលវេលាសង្គ្រាម អត់មានចាប់គូនឹងគេ?

សារ៉េន ៖ អត់ ។

វណ្ណៈ ៖ ចុះមីងៗនៅមើល មីងអត់បានទៅខាងម៉ាឡៃអីនឹងគេ នៅខាងឡែម នៅខាងចក្រីអីនឹងរហូតនឹងម៉ង?

សារ៉េន ៖ ខ្ញុំនៅចក្រីហើយ អត់មានបានទៅម៉ាឡៃ មកនៅមន្ទីរពេទ្យ៨១នឹង ជិតកន្លែងមន្ទីរគាកន សម្រាប់ទទួលអ្នករបួសនឹង ។

វណ្ណៈ ៖ ចុះមីងកាលនឹងអត់ចង់រត់ទៅស្រុកក្រៅទៅអី?

សារ៉េន ៖ ខ្ញុំទៅចូលទៅម្តង កាលវ៉ៃគ្នាចូលទៅជំរំៗ ។

វណ្ណៈ ៖ ជំរំអីគេ?

សារ៉េន ៖ ជំរំតាង៉ុក កាលនឹងគេកើតជំរំមុនដំបូង ស្រាប់ដល់គេហៅខ្ញុំមកវិញ ។

វណ្ណៈ ៖ ពីណាហៅ?

សារ៉េន ៖ នែក! ប្រធានៗកងទ័ព បើពេទ្យនាំគ្នាទៅអស់ មានអ្នកណាព្យាបាលកងទ័ពៗអត់វ៉ៃគ្មាន អ្នកណាវ៉ៃ ព្រោះនឹកឃើញថាកងទ័ពនាំគ្នាមកវិញមក កុំអីបានទៅក្រៅ ។

វណ្ណៈ ៖ កុំអីពួកមីងទៅក្រៅ?

សារ៉េន ៖ ទៅអស់ហើយ គេដឹកយកទៅ ប៉ុនដល់ហើយប្រធានៗវរសេនាធំនឹង ចូលទៅអង្វរនៅជំរំ ឲ្យមកវិញ ទៅបានម៉ាយប់គេទៅតាម ។

វណ្ណៈ ៖ គេដឹង គេទៅអង្វរទន់ចិត្តមកវិញ?

សារ៉េន ៖ មកវិញ អាណិតកងទ័ព ។

វណ្ណៈ ៖ កុំអីទៅថៃ ទៅអាមេរិចបាត់?

សារ៉េន ៖ ទៅបានចេញទៅក្រៅអស់ហើយ នាំគ្នាពេទ្យទៅឆុល ទៅជំរំ ថាទៅសម្ពាសន៍ទៅ ស្រាប់ ដល់គេទៅតាមអង្វរនិយាយនយោបាយចេះចុះនាំគ្នាទៅ ទៅបានម៉ាយប់ ។

វណ្ណៈ ៖ ពីណាគេអ្នកនិយាយ?

សារ៉េន ៖ គាត់ស្លាប់បាត់ហើយ គាត់ ។

វណ្ណៈ ៖ ពីណាគេ?

សារ៉េន ៖ ឈ្មោះ ពូយ៉ានៗ គាត់ស្លាប់បាត់ហើយ ។

វណ្ណៈ ៖ គាត់ស្លាប់ដោយសារ?

សារ៉េន ៖ គាត់ស្លាប់ឥឡូវនឹង ទើបនឹងស្លាប់ដែរនឹង គាត់ស្លាប់ឥឡូវស្លាប់ជម្ងឺ ។

វណ្ណៈ ៖ ចុះមីងកាលមីងមកដំបូងអីនៅម្តុំចក្រី សាស្តាអីវ៉ាន់នឹងគ្មានវាលចឹង?

សារ៉េន ៖ អត់ទេ នេះសុទ្ធព្រៃមីន ព្រៃខ្លា ព្រៃដំរី ។ ក្រោយមកខ្ញុំភ្លេចទៅនៅនឹង នៅម្តុំផ្សារ......... មិនយូនវ៉ៃឆ្នាំ៨៥ ពួកខ្ញុំរត់ចូលទៅនៅដីថៃ ចាំ!ទៅនៅដីថៃ ។

វណ្ណៈ : ចឹងបានគេហៅថាជំរំ៨៥ ?

សារ៉េន : អត់ទេ នៅដីថៃនេះ នៅក្រោយភ្នំតាង៉ុកនេះ ទៅនៅនឹងបានប៉ុន្មានឆ្នាំទេ ដល់ឆ្នាំ៩០ តាំង ពី៨៥មកដល់ឆ្នាំ៩០ បានចេញពីដីថៃមក បានចេញមកនៅ៣២ ។

វណ្ណៈ : ចុះមីងមកដល់នៅនេះឆ្នាំណា? មកនៅភ្នំព្រីក្សនេះ?

សារ៉េន : មកហេ៎?

វណ្ណៈ : បាទ!

សារ៉េន : ៩៨ មកនៅភ្នំព្រីក្សនេះ ។

វណ្ណៈ : ហា៎! គេផ្តាច់ខ្លួនហើយ?

សារ៉េន : ចា៎! ៩៨ ។

វណ្ណៈ : ៩៨ហើយ?

សារ៉េន : ចា៎!

វណ្ណៈ : ផ្តាច់ខ្លួនហើយ?

សារ៉េន : ចា៎!

វណ្ណៈ : ដូចឥឡូវដូចថាដំរីមានអស់ទៅណា អស់ព្រៃអស់អី មិនដឹងរត់ទៅខាងណា?

សារ៉េន : ដឹងទៅណា អត់ដែលឃើញ ។

វណ្ណៈ : ប៉ុនកាលពីដើមឡើយមីងដែលឃើញទេ?

សារ៉េន : អត់ដែលឃើញដំរី ឃើញតែអាចម៍វា ដើរព្រៃឃើញតែអាចម៍ ។

វណ្ណៈ : វាមិនឲ្យយើងឃើញដែរ?

សារ៉េន : អត់ដែលឃើញដំរី ។

វណ្ណៈ : ប៉ុនមីងជឿងថានៅក្នុងព្រៃនឹងមាន?

សារ៉េន : មាន ។

វណ្ណៈ : មានខ្លាមានអី?

សារ៉េន : មានខ្លាៗមាន ។

វណ្ណៈ : សព្វថ្ងៃនឹងមិនស្រួលមាននៅលើភ្នំលើអី?

សារ៉េន : អូ! អាចនៅដីថៃ ។ នៅតាមភ្នំយើងនេះក៏មានដែរ ។

វណ្ណៈ : ចុះដើមឈើកាលមកដល់ដំបូងមានទេ អាធំចង់ប៉ុនពាងអីមាន?

សារ៉េន ៖ ហ៎! ដើមធំៗណាស់ ដើមបេង ដើមស្រឡៅ ដើមសុទ្ធតែបេង ។

វណ្ណៈ ៖ សុទ្ធអោបៗធំណាស់?

សារ៉េន ៖ ចា៎! ប៉ុនអត់ឈ្មោះអ្នកអារៗទាល់តែវាលខ្ទេច ។

វណ្ណៈ ៖ តាមពិតព្រៃឈើអស់នឹងគេអារយកទៅលក់នៅខាងថៃ?

សារ៉េន ៖ ថៃ យកទៅថៃ ។

វណ្ណៈ ៖ គិតទៅឈើ អស់មិនតិច ម៉ាជំនៀរព្រំដែនអស់រលីងឥឡូវ ។

សារ៉េន ៖ ច្រើនណាស់ឈើ ។

វណ្ណៈ ៖ ក្មេងៗក្រោយលែងស្គាល់ឈើធ្វើផ្ទះៗថ្មវិញហើយ ។

សារ៉េន ៖ ចា៎! ប៉ុនអ្នកណាលក់បានៗតែអ្នកនឹង អ្នកណាអត់ៗឈើនឹង ។

វណ្ណៈ ៖ បានតាមមេៗ?

សារ៉េន ៖ ចា៎! មេៗនឹង កូនៗមានបានអី ។

វណ្ណៈ ៖ អត់ហ៊ានទេនេះ ។ ទាល់តែកូនធ្វើ ក៏គេចាប់ដែរតាមមើល?

សារ៉េន ៖ ចាប់អត់ហ៊ានទេ គេធ្វើមានបទពិសោធន៍របស់គេ ។

វណ្ណៈ ៖ ចឹងមីងប្រណែនអត់ចឹង បើគេធ្វើបាន មីងធ្វើអត់បាន ហើយតស៊ូដែរ?

សារ៉េន ៖ អត់ទេ អត់ជំនាន់នឹងដូចថាមានជំហរលេះបង់ អត់គិតរឿងកម្មសិទ្ធិផង ។

វណ្ណៈ ៖ ឥឡូវគិតតិច?

សារ៉េន ៖ ឥឡូវ ដល់ឥឡូវគិត ។

វណ្ណៈ ៖ ពីមុនអត់ចង់បានអីទេ មីងនេះ?

សារ៉េន ៖ ចា៎! ដល់ឥឡូវគេចាយលុយស្អីក៏ទិញៗ ។

វណ្ណៈ ៖ យើងត្រូវតែ?

សារ៉េន ៖ ចា៎! ពីមុនរបស់សុំគ្នាបានម៉ាសេរី អត់ទេ ហើយខ្ញុំមានជំហរមួយថា មិនគេងប្រវ័ណ្ឌដូចថា ដំណាំអីៗនឹង ខ្ញុំមិនដែលលក់ទេ ឲ្យហូបចុះ យើងធ្លាប់ហូបនៅរស់ម៉ាជីវិតហើយ ។ ដល់ ពេលចឹងដូចថាគ្នា លក់ឲ្យគ្នាវាមិនកើត ធ្លាប់តែរួមៗ ។

វណ្ណៈ ៖ ចឹងកាលមីងធ្វើនឹង ធ្វើដោយគ្មានប្រាក់ខែ ប្រាក់ថ្ងៃអីទេ?

សារ៉េន ៖ អត់ៗដែលបានអីម៉ារៀល ។

វណ្ណៈ : បានតែកម្ទាំង ហើយហូបត្រីខជាមួយបន្លែចិនទៅ?

សារ៉េន : ចាំ! អត់ដែលបានទេ ប៉ុនជំនាន់ខ្ញុំធ្វើនឹង មិនដូចពេទ្យឥឡូវ ណាលោកពូ បើថាលាងរបួស ធាក់ម៉ាជើងធ្លាក់ដី ងើបឡើងជូតទឹកភ្នែកញញឹមមកលាងវិញ អត់មានសម្ដីអាក្រក់ដាក់អ្នក របួសបានទេ ។

វណ្ណៈ : ចិនអ្នករបួសម៉េចធាក់យើង?

សារ៉េន : ឈឺ ចុះឈឺចុកចាប់ ចេះធាក់យើង មិនមែនថាអ្នករបួសធាក់យើងហើយ យើងដើរចេញ ទៅកន្លែងទៅអីអត់បានទេ ត្រូវមានជំហរមួយថែទាំដូចឪពុកម្ដាយចិន ។ គ្នាខំទៅរៀនៅ សមរភូមិមានឪពុកម្ដាយណាមក អត់បងប្អូនណាមក អត់បងប្អូនណា មានតែពេទ្យនឹង ហើយធ្វើជាឪពុកម្ដាយរបស់គេ ។ ហើយចិនយើងមានជំហរមួយហៅថា ជំហរអធន គេ ធាក់ម៉ាជើងដល់ដីងើបឡើងជូតទាំងទឹកភ្នែកឡើងមកលាងវិញដដែល ។

វណ្ណៈ : ចិនអត់មានគំរោះគំរើយដេរអីទេ?

សារ៉េន : អត់ទេ ។

វណ្ណៈ : ចិនមានៗអ្នករបួសធាក់ពេទ្យដែរ?

សារ៉េន : អឺ! ធាក់ច្រើនណាស់ ជំនាន់ខ្ញុំ សង្គ្រាម៥ឆ្នាំ ធាក់អស់ទាស់ហើយ ។

វណ្ណៈ : អាពេលលាង យើងអត់មានចាក់ថ្នាំស្ពឹកថ្នាំអីទេ?

សារ៉េន : អត់ទេ ។

វណ្ណៈ : យើងលាងឆៅ?

សារ៉េន : ធម្មតារបួសសោះសាច់ចេះតែឈឺហើយ ។ ហើយយើងលាងដៃធ្ងន់តិចវាឈឺហើយ ចេះ ធាក់ ដល់យើងប្រកាន់ជំហរនឹង បើមិនចិនយើងលាងថ្នមៗឲ្យគាត់ ។

វណ្ណៈ : ចិនដូចថាបើសិនជាជាន់មីងជាន់អីបញ្ជូនទៅថៃ?

សារ៉េន : អត់ គាត់នៅកន្លែងខ្ញុំជាន់មីន ។

វណ្ណៈ : ខ្លះគេថាបើគាត់នៅថៃវិញ គេកាត់ហើយដល់ពេលនឹងគេរុំតែម្ដង អត់លាងទេ ជាម៉ង?

សារ៉េន : នែក! ថៃគេអត់មានលាងទេ ហើយយើងខ្មែរយើង នៅនេះក៏អត់លាងដែរ ទាល់តែរបួស នឹងក្លាយបានយើងលាង យើងត្រាំ ដូចថាវាចង់ចូលអាប់សែ វារបួសក្លាយនឹងណា ច្រើម ។

វណ្ណៈ : អានឹងមកពីយើងកាត់អត់អស់អាជាតិរំសេវ វាស៊ីនឹង?

សារ៉េន ៖ កាត់អត់អស់ ដូនណានៅមានអាសាច់ខ្ញុំនឹងណា យើងយកអត់អស់ដល់ពេលយើងកាត់ហើយទៅដេរបិទទៅវាបង្កូរោគ វាមានខ្ទុះមានអីចឹងទៅ ។

វណ្ណៈ ៖ អានឹងលាង?

សារ៉េន ៖ ទាល់តែយើង វាហើមចឹងទៅ ដល់តែពេលនឹងយើងត្រូវលាង ។

វណ្ណៈ ៖ អានឹងឈឺទេ?

សារ៉េន ៖ ឈឺគ្រាំ ដាក់ទុកដាក់អី ។

វណ្ណៈ ៖ តែបើសិនជាយើងកាត់តែម្តងស្អាត?

សារ៉េន ៖ ស្អាតមិនបាច់លាងទេ ៧ថ្ងៃកាត់ដេសម៉ង ។

វណ្ណៈ ៖ កាត់លឿន?

សារ៉េន ៖ កាត់មានពិបាកអីកាត់ម៉ាភ្លែត ។

វណ្ណៈ ៖ ប៉ុនដឹងខ្លួនហើយ មិនស្រួលយំអ្នកនេះនឹង?

សារ៉េន ៖ អឺ!យំហើយ ស្តាយ ។

វណ្ណៈ ៖ ស្តាយជើង?

សារ៉េន ៖ ចាំ!

វណ្ណៈ ៖ តែបើសិនជាយើងមិនកាត់អត់បាន?

សារ៉េន ៖ អត់ទេត្រូវតែកាត់ បើខ្ទេចអស់ហើយ យើងមិនកាត់នេះ បើជាន់ក្រោមនេះកាត់ត្រឹមនេះ

វណ្ណៈ ៖ ចឹងបើអ្នករបួសដោយសារដាច់ជើងច្រើនដែរ?

សារ៉េន ៖ ច្រើន ។

វណ្ណៈ ៖ ចុះក្រោយមកទៀត ឧបមាថាពេលយើងចង់រានដី យើងចង់បានរានដីរានអី កាប់ឆ្ការព្រៃនឹង អានឹងមានគ្រោះថ្នាក់ម៉ាសារទៀត?

សារ៉េន ៖ មាន ម៉ាសារទៀត ។

វណ្ណៈ ៖ ម៉ាសារទៀត?

សារ៉េន ៖ ចាំ! មានម៉ាសារទៀត ។

វណ្ណៈ ៖ យើងអត់ចាំស៊ីម៉ាក់អីមកជួយដោះសិន?

សារ៉េន ៖ ចាំស៊ីម៉ាក់យូរណាស់ បើអត់ទៅកាប់ចេះកាប់រាវៗបណ្តើរៗ ។

វណ្ណៈ ៖ ប៉ុនអ្នកនៅ អ្នកដែលមកនៅនេះដំបូងមុន គឺបានដីច្រើនៗណាស់មីងនេះ?

សារ៉េន ៖ អ្នកបានច្រើនៗ ប៉ុនអ្នកខ្លះលក់អស់វិញហើយ អ្នកខ្លះលក់ ។

វណ្ណៈ ៖ លក់អស់វិញធូនធូរហើយ?

សារ៉េន ៖ ចា៎! ធូន ។

វណ្ណៈ ៖ ពិបាករកនេះណា បើយើងទុកដីនៅអីយើងនៅបានធ្វើអីបាន?

សារ៉េន ៖ ដូចខ្ញុំអីចេះទុកៗលេងៗចឹងតិចៗទៅ ។

វណ្ណៈ ៖ មីងបានប៉ុន្មានហិចតា?

សារ៉េន ៖ ដី១០ហិចតា ។

វណ្ណៈ ៖ ១០ហិចតាឥឡូវមិនបានលុយតិចទេ ច្រើន?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ឥឡូវម៉ាហិចតា១ថ្លៃ?

សារ៉េន ៖ ថ្លៃ ប៉ុនគ្រាន់ទុកដាំចឹង យើងដាំតិចៗចឹង ។

វណ្ណៈ ៖ ដាំដំឡូងដាំអី?

សារ៉េន ៖ ដាំដំឡូង ដាំពោត បើម៉ា១០ហិចតាយើងធ្វើត្រូវបាន៨សែនដាងចឹងដែរ ។

វណ្ណៈ ៖ តែឥឡូវមីនអីលែងមានលែអីទៀត?

សារ៉េន ៖ អត់ទេ ។

វណ្ណៈ ៖ អស់ហើយ គេដោះអស់ហើយ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចុះមីងដើរទៅចឹងៗនៅជិតផ្ទះចឹង នៅមានការភ័យខ្លាច?

សារ៉េន ៖ អត់ទេ ។

វណ្ណៈ ៖ ឈប់ភ័យហើយ?

សារ៉េន ៖ ខ្ញុំពីមុនសុទ្ធតែរៀនរាវដោះមីន ។

វណ្ណៈ ៖ មីងចេះដោះដែរ?

សារ៉េន ៖ មីងដោះតើ ។

វណ្ណៈ ៖ ហា៎! មីងបើមើលឃើញចឹងមីងដោះបាន?

សារ៉េន ៖ អឺ!ដោះ សុទ្ធតែមីងៗដោះពីមុន ។

វណ្ណៈ ៖ អត់ខ្លាចទេ បើយើងឆ្កើសមិនស្រួលៗផ្ទុះ?

សារ៉េន ៖ ដោះតែមីនប្រអប់ មីនស្អុរ តែ៦៩អត់ហ៊ានទេ ។

វណ្ណៈ ៖ ៦៩មីនអីគេ មីនគោន?

សារ៉េន ៖ ៦៩ អាមីន៦៩មីនប៉ុនៗនេះ ។

វណ្ណៈ ៖ អានឹងមីនសម្រាប់ដាក់អី?

សារ៉េន ៖ អានឹងមីនជាន់ មីនដាក់ខ្សែដាក់អី មិនស្រួលសុទ្ធតែផ្ទុះ តែថាប៉ះហើយសុទ្ធម្នាក់ៗនៅនឹង ។

វណ្ណៈ ៖ ចុះបើអាមីនស្អុរតូចៗអីយើងដោះបាន?

សារ៉េន ៖ ដោះបាន រៀបប្រអប់នឹង យើងដោះ ។

វណ្ណៈ ៖ ចុះអាមីងក្រៅពីពេទ្យបេះដោះមីន ពីណាបង្ហាត់ដោះ?

សារ៉េន ៖ មានបង្ហាត់អី ពូៗ មើលពូៗដោះ ។

វណ្ណៈ ៖ មើលដោះបេះ?

សារ៉េន ៖ មើលពូដោះ ចុះធ្វើស្អីៗធ្វើបាន ទម្រាំមើលចឹងៗដោះទៅ ។

វណ្ណៈ ៖ ដោះគេឆ្កើសម៉េចទៅ គេឆ្កើសរបៀបម៉េច?

សារ៉េន ៖ គេឆ្កើសថ្មមៗយក ខ្ញុំពិបាកប្រាប់ណាស់ អត់ធ្វើ ។

វណ្ណៈ ៖ តែអានឹងបើយើងជាន់ចឹង ដឹងថាបញ្ហា យើងដកជើងឲ្យលឿន?

សារ៉េន ៖ អត់ទេ ប៉ែលយើងដាក់ម៉ាសេរី អាប៉ែលប៉ុនៗនេះ ដាក់ដល់អានឹងហើយ យើងឈូសៗវាឈូសចុះក្រោមចឹង ឈូសៗ បើថាបះហើយយើងយកអាប៉ែលនឹង ចាក់ពីក្រោមមកលើកមក ។

វណ្ណៈ ៖ លើកមកដល់លើលែងអីហើយ?

សារ៉េន ៖ លើកមកដល់លើលែងអី ។

វណ្ណៈ ៖ តែបើយើងជាន់អត់បានទេ?

សារ៉េន ៖ ជាន់ផ្ទុះផ្តាច់ជើង ។ ដល់យើងឆ្កើសបានចឹង យើងយកមកគរម្ដុំៗដុតភ្លើងទៅ ។

វណ្ណៈ ៖ វាផ្ទុះតែ អត់មានផ្ទុះទៅឆ្ងាយទេ?

សារ៉េន ៖ អត់ទេ ។

វណ្ណៈ ៖ ចឹងអឺ! ពីដើមឡើយនៅនឹងគ្មានភូមិទេ កាលពីសង្គម ជំនាន់សម្តេចសីហនុអីអត់មាន?

សារ៉េន ៖ អត់មានទេ សុទ្ធតែព្រៃសុទ្ធ ខ្ញុំរត់មកសុទ្ធតែព្រៃសុទ្ធ ។

វណ្ណៈ ៖ ចុះវត្តអីដូចថាខ្ញុំជិះមកឃើញវត្តអី?

សារ៉េន ៖ វត្តទើបនឹងកសាងឥឡូវនឹង ។

វណ្ណៈ ៖ ទើបកសាង?

សារ៉េន ៖ ចាំ! ទើបកសាង គ្មានវត្តណា អត់ផងពីមុន ។

វណ្ណៈ ៖ ចុះដូចថាមានភូមិៗដែលកើតមកដល់សព្វថ្ងៃនេះ គេទើបបង្កើតពេលផ្លាច់ខ្លួនហើយទេ?

សារ៉េន ៖ ចាំ!

វណ្ណៈ ៖ ពីមុនមកកន្លែងនឹងគេហៅអីដែរ អត់ដឹង?

សារ៉េន ៖ អត់ ។

វណ្ណៈ ៖ អត់មានឈ្មោះមានអីទេ ពីមុនមកអត់មានឈ្មោះ?

សារ៉េន ៖ មានតែតាមកង ដល់ពេលផ្តាច់ខ្លួនគេចែកក្នុងកងជាភូមិៗណា ភូមិនេះភូមិនោះ ។

វណ្ណៈ ៖ ចឹងនៅភ្នំព្រឹក្សគេហៅតំបន់អីដែរ តំបន់២៥០?

សារ៉េន ៖ ចាំ! តំបន់២៥០ ។

វណ្ណៈ ៖ ហើយនឹងបើនៅម៉ាឡៃប៉ុន្មាន? ចុះតំបន់៣២នៅណាវិញ?

សារ៉េន ៖ ៣២នឹង ២៥០នឹង នៅដើង គ្រាន់មន្ទីរ៣២ តែតំបន់២៥០ ។

វណ្ណៈ ៖ អត់មានឈ្មោះម៉ាឡៃ អត់មានឈ្មោះផ្សេង?

សារ៉េន ៖ អត់ទេ ម៉ាឡៃផ្សេង ប៉ៃលិនផ្សេង ។

វណ្ណៈ ៖ អឺ! អត់មានឈ្មោះភ្នំព្រឹក្ស អត់មានស្រុកភ្នំព្រឹក្សអីចឹង?

សារ៉េន ៖ អត់ទេ ទើបនឹងកើតថ្មី ។

វណ្ណៈ ៖ ចឹងទើបនឹងកើតថ្មីទេ ។ ចឹងកាលសមាហរណកម្មហើយ ពេលដែលខ្មែរក្រហមព្រមធ្វើសមាហរណកម្ម មីងកាលនឹងមីងភ័យទេ?

សារ៉េន ៖ អត់ខ្ញុំអត់ភ័យផង ខ្ញុំបន់ឡុងកភាជ្យ ។

វណ្ណៈ ៖ បន់ឡុងកភាជ្យកើត?

សារ៉េន ៖ បន់ឡូចប់សង្គ្រាម ។

វណ្ណៈ ៖ ថុញថប់ណានឹងសង្គ្រាម?

សារ៉េន ៖ ថុញខ្លាំងណាស់ វាឆ្អែតឆ្អល់ហើយ ។

វណ្ណៈ ៖ ចុះដល់ពេល៩៦ហើយ បងប្អូនយើងចាប់ផ្តើមនាំគ្នាសង់ផ្ទះសង់អីទៅ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចុះពីមុនមកអត់សង់ផ្ទះធំៗចេះ?

សារ៉េន ៖ ចា៎! ផ្ទះតូចៗ ចុះត្រៀមរត់ ។

វណ្ណៈ ៖ ត្រៀមរត់ មិនពិតប្រាកដផង?

សារ៉េន ៖ ចា៎! ត្រៀមរត់ ។

វណ្ណៈ ៖ ដល់ឥឡូវចង់សង់ផ្ទះឈើធំៗចេះអត់មានឈើ ។

សារ៉េន ៖ អត់មានឈើ ។

វណ្ណៈ ៖ នេះធ្វើផ្ទះវីឡាថ្មម៊ង ។

សារ៉េន ៖ ហើយកុំបានគុណផ្ដាច់ខ្លួន ក៏អត់បានស្គាល់ម៉ែ តាំងពីចេញពីផ្ទះមករហូតទល់ផ្ដាច់ខ្លួនទើប បានជួបម៉ែ គិតមើលអាយុមិនចេះតិចបានជួប ។

វណ្ណៈ ៖ ចឹងដូចថាតាំងពីផ្ដាច់ខ្លួនហើយ មីងទៅលេងស្រុកបានប៉ុន្មានដង?

សារ៉េន ៖ ផ្ដាច់ខ្លួនហើយ យីទៅញឹកណាស់ឥឡូវ ។

វណ្ណៈ ៖ តាំងពីទៅប្រហែលប៉ុន្មានដង?

សារ៉េន ៖ ទៅប្រហែលចូល១០ដងហើយដឹង ផ្ដាច់ខ្លួនហើយមកផាកទៅៗជូនណាម៉ាឆ្នាំ២ដង ម៉ាឆ្នាំ ម៉ាដងទៅញឹកណាស់ ។

វណ្ណៈ ៖ ចុះមីងទៅថ្ងៃក្រោយដូចថាមីងចាស់តិចទៀតទៅ ម៉េចទៅ មីងចង់នៅនឹងរហូត ក៏ចង់ទៅ រស់នៅស្រុកកំណើតវិញ?

សារ៉េន ៖ ខ្ញុំចង់នៅនេះ ។

វណ្ណៈ ៖ ចង់នៅភ្នំព្រឹក្សនឹង?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ លែងអត់ចង់ទៅស្រុកទេនេះ?

សារ៉េន ៖ ខ្ញុំអត់ចេះនៅទេ ស្រុក ។

វណ្ណៈ ៖ កូនមីងប៉ុន្មានហើយ តូចនឹង?

សារ៉េន ៖ ទៅណាបាត់ហើយមិញ ។

វណ្ណៈ ៖ ធំនៅ?

សារ៉េន ៖ ធំហើយ ឈ្មោះធីតា អាយុ១៣ឆ្នាំ ។

វណ្ណៈ : ១៣ឆ្នាំ?

សារ៉ែន : ចា៎!

វណ្ណៈ : ចឹងបោះជំរំកូនចៅនៅនេះហើយ ។

សារ៉ែន : ចា៎! អត់ទៅណាទេ នៅព្រំដែន ។

វណ្ណៈ : បើថាថ្ងៃក្រោយយើងមានផ្លូវជាតិចឹងហើយ យើងចង់ទៅលេងស្រុក ទៅវីបគ្មានពិបាកអី លើកមុនផ្លូវពិបាក ប្រើលុយអស់ច្រើន ។ ដល់ថ្ងៃក្រោយទៅមានឡានក្រុងរត់ អស់លុយតិច ។

សារ៉ែន : ចា៎! អស់លុយតិច ។

វណ្ណៈ : បានទៅលេង ។ ចុះមីងគិតថាការដែលសម័យមីងតស៊ូធ្វើសង្គ្រាមនឹង វាមានការដូចថាស្ករ ប៊ីចេង អង្ករអីគេឲ្យហូបស្រាប់ ដល់ឥឡូវមីងខំរកដោយខ្លួនឯងចឹង ។ តើមីងគិតថា ការខំរកដោយខ្លួនឯង ឬក៏ចាំហូបស្រាប់នឹង ២នឹងមួយណាស្រួលរស់នៅជាង បើចិត្តរបស់មីង?

សារ៉ែន : ខ្ញុំថារកខ្លួនឯងស្រួលរស់នៅជាង ។

វណ្ណៈ : ចឹងឥឡូវនឹងស្រួលរស់នៅជាង?

សារ៉ែន : ចា៎!

វណ្ណៈ : ប៉ុន្តែក៏មានអ្នកខ្លះថា អឺ!ពីមុនមិនខ្វល់ទេ តែដល់គេចែកអង្ករឲ្យហូបរហូតគ្មានគិតគូទេពីមុន ស្រួលជាង ខ្លះក៏គេមានយោបល់ចឹងដែរ ។ តែបើទស្សនៈរបស់មីងវិញយ៉ាងម៉េចដែរ?

សារ៉ែន : ខ្ញុំពីមុន ស្រួលអ្នកស្រួល បើខ្ញុំធ្វើពេទ្យលំបាក អត់ងងុយទាំងយប់ទាំងថ្ងៃ ពិតមែនហូបបាយ អង្ករបើក ប៊ីចេងបើក ប្រហិតបើក អំបិលបើកមែន តែយើងបម្រើការងារអត់មានឈប់ទេ ។ ហើយទាល់ឥឡូវយើងរកបានខ្លួនឯងចេះ ចង់យើងធ្វើក៏បាន ចង់យើងមិន ធ្វើក៏បាន ។

វណ្ណៈ : ចឹងឥឡូវនឹងស្រួលជាង?

សារ៉ែន : ខ្ញុំថាឥឡូវស្រួលជាង ។

វណ្ណៈ : ចឹងមីងចង់ឲ្យប្រទេសជាតិអភិវឌ្ឍន៍ទៅរកខាងមុខទៀតពីមុន
ហើយឬក៏ឲ្យរីកចំរើនទៅមុខ?

សារ៉េន : អត់ទេ ឲ្យរីកចំរើនទៅមុខចុះ ។

វណ្ណៈ : អត់ចង់ត្រឡប់ក្រោយទេ?

សារ៉េន : បានជួបជុ អត់ទេ ខ្ញុំអត់ចង់ឲ្យត្រឡប់ក្រោយទេ ខ្ញុំឆ្អែតឆ្អល់ហើយ ។

វណ្ណៈ : ចឹងមីងគិតថា ចុះអ្នកស្រុកអ្នកភូមិនឹងគេប្រកបមុខរបរដាំដុះដូចដំឡូង ដូចជាពោតចឹងបាន ផលគេយកទៅលក់នៅថៃ?

សារ៉េន : ថៃមកទិញដល់ៗផ្ទះ ។

វណ្ណៈ : ចុះអ្នកស្រុកអ្នកភូមិនឹង មានប្រជាជនថ្មីមករស់នៅច្រើន?

សារ៉េន : ច្រើន ។

វណ្ណៈ : ដែលគេអ្នកមកថ្មីនឹង អត់មានដីធ្វើអីចឹង គេមកស៊ីឈ្នួល ឬក៏គេទៅណារកស៊ីឈ្នួលអីដែរ?

សារ៉េន : គេមកជួនណាមកស៊ីឈ្នួលនៅថៃ ជួនណាមកស៊ីឈ្នួលនៅនឹងយើងនឹង ។

វណ្ណៈ : ជួនកាលគេមានលុយ គេទិញដីអីទៅ?

សារ៉េន : ទិញដីទៅ ចំណូលមកច្រើនណាស់ ។

វណ្ណៈ : ប៉ុនអ្នកៗភូមិដូចថាដែលធ្លាប់នៅតាំងពី៧៩មក ភាគច្រើនគេមិនទៅរកស៊ីនៅថៃទេ?

សារ៉េន : អត់ទេ អត់ទៅទេអ្នកនៅចាស់អត់ទៅថៃទេ ។

វណ្ណៈ : ចឹងអ្នកថ្មីបានទៅរកស៊ីនៅថៃ?

សារ៉េន : ចា៎!

វណ្ណៈ : ចុះមីងមកដល់រាល់ថ្ងៃនេះ ដូចជាបងប្អូនអីមកស្នាក់នៅអីចឹង មកពីតាកែវមកអីស្នាក់នៅផ្ទះមីងអីទៅរកស៊ីអីចឹងបានដដែល ឬក៏គ្មានបងប្អូនមកជិតមីងទេ?

សារ៉េន : មកផ្ទះខ្ញុំមកពេញៗ ទើបតែចេញពីម្សិលមិញនឹង ។ សួររកជាងនៅតាកែវ ។

វណ្ណៈ : បាទ! អ្នកខាងក្នុងម៉ាចំនួន គ្នាយ៉ាប់ដែរ ខ្លះទៅបានដីថ្លៃចឹងទៅ លក់អស់អត់មានអីធ្វើនឹងពិបាកមែនទែន គេអត់ជួលយើងធ្វើការទៀត អត់មានអីស៊ី ។

សារ៉េន : អត់ទេ ព្រំដែននឹងយើងស្រួលរកមែនទែន ។

វណ្ណៈ : តែបើយើងដីគេឲ្យថ្លៃៗ ថៃមកទិញអី យើងលក់ឲ្យអស់ទៅ?

សារ៉េន : ចាំតែលក់ឲ្យ ថៃនឹង ។

វណ្ណៈ : ឈប់លក់ អត់មានលក់ បើលក់ក៏លក់មិនបានទេ រដ្ឋាភិបាលយើងគេមិនលក់ឲ្យទេ គេមិនឲ្យយើងលក់ទេ ។

សារ៉េន : លក់អីឲ្យថៃៗកំពុងសត្រូវជាមួយខ្មែរផង លក់ឲ្យគេ ។

វណ្ណៈ : ដល់ពេលក្រែងលរមានឈ្មួញណាធំៗមកទិញ ក៏យើងប្រុងប្រយ័ត្នដែរ មិនសូវលក់ដែរ យើងទុកខ្លះ ។

សារ៉េន : ឥឡូវនឹងវាមានមាស ឥឡូវមាសចាស់ៗជំនាន់ពីដើមថាមាសផុស ឥឡូវដល់ហើយ ។

វណ្ណៈ : ដល់ម៉េច?

សារ៉េន : ដល់ហើយ ជីកមួយតឹក វាបាន ។

វណ្ណៈ : ចង់និយាយថាឥឡូវនឹងមិនមែនមាសនៅក្នុងដីទេ មិនមែនមាសដែលកើតទេ មានដោយសារកម្លាំងយើងរក នៅក្នុងផលដំណាំនឹង ។

សារ៉េន : អត់ទេ មាសនៅក្នុងដីម៉ង ។

វណ្ណៈ : មាសនៅណា?

សារ៉េន : នេះ ។

វណ្ណៈ : ភ្នំអី?

សារ៉េន : ភ្នំយើងនឹង ឥឡូវជីកបានជីកខ្លះ ។

វណ្ណៈ : គេហៅភ្នំអីដែលមានមាសនឹង?

សារ៉េន : ភ្នំ៥៣ ។

វណ្ណៈ : ភ្នំ៦៣?

សារ៉េន : មិនមែន០៥ទេ ៥៣អានឹង ។

វណ្ណៈ : ភ្នំ៥៣?

សារ៉េន : ចាំ!

វណ្ណៈ : ភ្នំ៥៣ ព្ធថាឥឡូវថៃវាចង់បានដែរមែនអត់?

សារ៉េន : ថៃវាចង់បាន តែមាសក៏កើតមិនដឹងបានខាងណា ប៉ុនដល់យើងទំដែរ ។

វណ្ណៈ : ឥឡូវមានអ្នកគេទៅរក?

សារ៉េន : អូ! គេធ្វើបានណាស់ ។

វណ្ណៈ : ចុះមានអាជ្ញាធរឃាត់អី?

សារ៉េន :	ឃាត់អី អាជ្ញាធរធ្វើដែរ ទាហានធ្វើដែរ ធ្វើទាំងអស់គ្នា ដឹងអ្នកណាទៅឃាត់ ។

វណ្ណៈ :	គេដឹក?

សារ៉េន :	គេដឹក ។ ល៊់!កិនគេមានប្រដាប់កិនបាន គេធ្វើបានម្នាក់ៗរាប់តម្លឹង គេមានប្រដាប់ ។

វណ្ណៈ :	ចុះមានមាស?

សារ៉េន :	ចា៎! អ្នកអត់ៗគេអត់ឲ្យអត់ ។

វណ្ណៈ :	សព្វថ្ងៃទាហានធ្វើ?

សារ៉េន :	ទាហានអី ប៉ូលីស ។

វណ្ណៈ :	ចុះយើងមានម៉ាស៊ីនដឹកម៉ង់?

សារ៉េន :	ចា៎! មាសបើចំកន្លែងមាស ដូចកើបយក ដី១០០ មាស១០០ដីនឹងមាសស្មើ តែវាមាន ដិតអស់ វាមានម៉ាខ្សែៗវាសិន ។ កន្លែងណាដិតមានទាហាន ប៉ូលីសយក ហើយកន្លែង ណាអត់ គេឲ្យប្រជាជនយក ។

វណ្ណៈ :	គេដិតម៉េចគេដឹង?

សារ៉េន :	វ៉ែគេក្នុងដីវ៉ែ មានដឹងដីវ៉ែដិតគេស្គាល់ ។

វណ្ណៈ :	ចុះមានទាល់មានអ្នកជំនាញទៀត?

សារ៉េន :	សូម្បីតែប្រជាជនក៏ស្គាល់ដែរ ឥឡូវមិនបាច់ទេ ។

វណ្ណៈ :	អូ! ប្រជាជនក៏ចេះមើលដែរ?

សារ៉េន :	ចេះមើលទាំងអស់ ដិតណាស់មើល ។

វណ្ណៈ :	ឥឡូវគេយកបានច្រើន?

សារ៉េន :	យកបានរាប់តំម្លឹងនោះ កុំនិយាយរឿងកំប៉ិចកំប៉ុក ។

វណ្ណៈ :	ចឹងបានឮថាថៃចង់បានដែរ ឥឡូវ?

សារ៉េន :	ថ្ងៃចង់បាន....(ស្តាប់មិនបាន) ........ ។

វណ្ណៈ :	អានឹងគេហៅភ្នំ៥៣?

សារ៉េន :	៥៣ ប៉ុនមកខាងជើងចេះទេ មិនមែនចំអាភ្នំ៥៣ខ្ពស់នឹង ។

វណ្ណៈ :	វានៅក្នុងអូរ?

សារ៉េន :	អត់ក្នុងអូរទេ វាចំរាលចឹងម៉ង់ ដីទំនាប ក៏មានប្រជាជនណាឧស្សាហ៍ដីកនោះមហាដីក ។

វណ្ណៈ :	ប្រជាជនអត់ដីកចុះ?

សារ៉េន ៖ ប្រជាជនដឹកបានដោយសារអត់បានរត់ទៅតាមឪ អត់បានទៅស៊ីឈ្នួលថៃទេ បានដោះស្រាយជីវភាពនៅក្នុងនេះ ប្រជាជន ។

វណ្ណៈ ៖ ស៊ីបានតិចតួចដែរ?

សារ៉េន ៖ បានតិចៗ បើម៉ាស៊ីនគេធ្វើសុទ្ធរាប់តម្លឹង គ្រាន់តែដឹក ។

វណ្ណៈ ៖ ចុះគេដឹកទៅគេស្គាល់មាស?

សារ៉េន ៖ គេវែងៗទៅបើមាសគ្រាប់អាខ្លះវែងមកមាន៨ហ៊ុន ៥ហ៊ុន ២ហ៊ុន ១ហ៊ុន ។

វណ្ណៈ ៖ មាសម៉េង?

សារ៉េន ៖ មាសសាច់ នឹងចេញមកក្រហមឈាម ។

វណ្ណៈ ៖ យកទៅ ទឹកល្អៗ?

សារ៉េន ៖ អឺ! យកទៅដល់ដុតធ្វើយកម៉េង គេគិនថ្មអីគេគិតយកទាំងអស់ចេញមាស ។

វណ្ណៈ ៖ មីងដូចថាមកដល់បច្ចុប្បន្ននេះ ដោយសារថាកាលជំនាន់ខ្មែរក្រហមនឹង ថ្វីត្បិតតែខាងកងទ័ពបានហូបចុកគ្រប់គ្រាន់ ដូចខាងកម្មករនៅភ្នំពេញអីបានហូបចុកគ្រប់គ្រាន់ ដោយឡែកប្រជាជនខ្លះខាតនឹង មានការស្លាប់ប្រជាជនអស់ជាងម៉ាលាននាក់ ។ នឹងតាមអ្នកស្រាវជ្រាវរក គេរកឃើញថាប្រជាជនស្លាប់ជាងម៉ាលាននាក់នឹង ។ ចឹងហើយបានជាអង្គការសហប្រជាជាតិនឹង គេបង្កើតតុលាការមួយ សម្រាប់ជាមួយតុលាការខ្មែរយើងដែរសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ មីងមានបានដឹងទេថា សព្វថ្ងៃនឹងគេចាប់ពីណាខ្លះដាក់នៅកន្លែងតុលាការសព្វថ្ងៃ តុលាការកាត់ទោសខ្មែរក្រហម មីងបានដឹងទេ?

សារ៉េន ៖ មើលទូរទស្សន៍ដឹង ។

វណ្ណៈ ៖ ពីណាគេ?

សារ៉េន ៖ នែក! តានួន ជា, តាខៀវ សំផន, ហើយនែក!អ្នកស្រីអៀង ធីរិទ្ធ ហើយនែក! តាឌុច

វណ្ណៈ ៖ តាអៀង សារី?

សារ៉េន ៖ តាអៀង សារី ។

វណ្ណៈ ៖ ចុះមីយល់យ៉ាងម៉េចដែរដូចថា ការមានតុលាការនឹង វាជាការខុសឆ្គង ឬក៏ថាត្រឹមត្រូវហើយដល់ពេលមានតុលាការកាត់ទោសចឹងអី?

សារ៉េន ៖ អឺ! ធ្វើតាមច្បាប់ មិនដឹងម៉េច ។

វណ្ណៈ ៖ នឹងមីងគិតថាធ្វើតាមច្បាប់?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ បើច្បាប់រកឃើញថាគាត់មានកំហុស អានឹងជារឿងរបស់គាត់?

សារ៉េន ៖ ជារឿងរបស់គាត់ យើងអត់ដឹងទេ យើងប្រជាពលរដ្ឋ។

វណ្ណៈ ៖ យើងប្រជាពលរដ្ឋ យើងមិនដឹងទេ?

សារ៉េន ៖ ចា៎!

វណ្ណៈ ៖ ចុះគេថាកាលនឹងទាក់ទងតាសុន សេនៗគាត់មកនឹង គេថាគាត់កាច ឆ្លើយថាម៉េច?

សារ៉េន ៖ តាសុន សេននឹង មហាកំពូលកាចក្នុងពិភពគុណហើយម៉ាជំនាន់មេដឹកនាំខ្មែរក្រហម មានតែតាសុន សេន។

វណ្ណៈ ៖ ចុះមីងដឹងថាគាត់នៅសម័យខ្មែរក្រហមគាត់ធ្វើអីដែរ?

សារ៉េន ៖ តាសុន សេន?

វណ្ណៈ ៖ បាទ!

សារ៉េន ៖ ធ្វើធំដូចតាប៉ុល ពត ដែរ មិនដឹងរងទីប៉ុន្មាន ខ្ញុំអត់ដឹងដែរ ប៉ុនគាត់ធ្វើធំ ខ្សែគាត់ជាមួយគ្នា ជាមួយតាអៀង សារី។

វណ្ណៈ ៖ តាសុន សេន គាត់នៅក្រសួងការបរទេស ហើយគាត់ក៏ជាប្រធានគុកទួលស្លែងធំដែរ កន្លែងសម្លាប់មនុស្ស។

សារ៉េន ៖ ចា៎! កាចណាស់។

វណ្ណៈ ៖ គាត់ប្រធានរបស់ឌុច។ ចឹងតាសុន សេន ពេលចប់ហើយគាត់នៅតែកាចដដែល ក្រោយ ៧៩ គាត់មានចរិតកាច?

សារ៉េន ៖ អឺ! ម៉ូតូក៏ដក រទេះគោក៏ដក មានរទេះគោក៏ដកដែរ មិនបាច់ថាឡានៗក៏ដកៗ ដកយកទៅ តំរៀបគ្នានៅ៣២នោះ។ ហើយប្រេះចាប់អស់ហើយ សុខចិត្តឲ្យខូចឡានប្រជាជន។

វណ្ណៈ ៖ ហេតុអីបានដក?

សារ៉េន ៖ នេះមនុស្សខូច កាចម៉ង។ អ្នកណាក៏ខ្លាច ពិតមែនខ្ញុំធ្វើពេទ្យមែន តែខ្លាចៗតាសុន សេន យកទៅវ៉ៃចោល គាត់កាច។

វណ្ណៈ ៖ គេថា ប្រជាជនមកពីក្នុង តែទ័ពចាប់បាន គាត់ឲ្យសម្លាប់ទៀត?

សារ៉េន ៖ ចា៎!

វណ្ណៈ : ចឹងមែនដែរអត់?

សារ៉េន : ចាំ! គាត់កាចណាស់ មិនបានទេ ។

វណ្ណៈ : ចឹងដល់នៅអ៊ីដែលគាត់កាច ចឹងមីងថាដល់ពេលគេបាញ់សម្លាប់គ្មានសល់មួយពូជ ទាំងកូនទាំងចៅប្រពន្ធគាត់ មីងថាអានឹងជាកម្មពៀរ ឬក៏យ៉ាងម៉េចដែរ បើមីងគិត?

សារ៉េន : ខ្ញុំថាកម្មពៀររបស់គាត់ ខ្ញុំថាបើនិយាយពីធម៌ព្រះវិញ គាត់ថាគាត់ធ្វើអាក្រក់ផលអាក្រក់ហុចឲ្យគាត់ ។

វណ្ណៈ : ហុចឲ្យ?

សារ៉េន : ហុចឲ្យមិនបាច់ជាតិមុខ ប្រហែលជាតិនៅ ហើយប្រជាជននៅនេះអ្នកនៅចាស់ ដែលគាត់ធ្វើបាបខ្លាំង គ្មានអ្នកណាស្រណោះប៉ុន្មានសរសៃសក់ ។ វេទនាធ្វើបាបណាស់ សូម្បីតែពួកពេទ្យខ្ញុំក៏គាត់ធ្វើបាប ។

វណ្ណៈ : ចឹងសុន សេន គាត់សាហាវ?

សារ៉េន : សាហាវណាស់ ស្លាប់ទៅគ្មានអ្នកណាស្រណោះទេ ។

វណ្ណៈ : ចឹងពេលគាត់ស្លាប់នឹង គ្មានអ្នកណាជួយអាណិត?

សារ៉េន : អត់រលីង មានតែបញ្ជូនថែម គ្មានអ្នកណាអាណិតគាត់ទេ ។

វណ្ណៈ : គិតថាចឹងដែរ មើលគេសម្លាប់ គាត់តែចាប់គេៗទាំងប្រពន្ធកូនដែរ ។

សារ៉េន : ចាប់ទាំងអស់ ដែលថាយកប្ដី យកប្រពន្ធយកវៃចោលដែរ ទាំងកូនទៀត ។

វណ្ណៈ : ហើយកូនគេតូចៗកំពស់នឹង គ្នាដឹងអីជំនាន់នឹង ។

សារ៉េន : ដឹងអីផង ។

វណ្ណៈ : ហើយយើងយកទៅសម្លាប់ទាំងអស់ ។

សារ៉េន : ចាំ!

វណ្ណៈ : ចឹងបានគាត់ស្លាប់នេះ ស្លាប់គ្មានសល់ដែរ ទាំងកូនទាំងចៅគេបាញ់ចោលទាំងអស់ ។

សារ៉េន : អត់ ពៀរឃើញភ្លាមៗ ។

វណ្ណៈ : ពៀរឃើញភ្លាមៗ?

សារ៉េន : ចាំ!

វណ្ណៈ : បើគិតតាមធម៌ព្រះពុទ្ធវិញ?

សារ៉េន : ចាំ!

វណ្ណៈ :	តើដូចថាមកដល់បច្ចុប្បន្ននេះ យើងមានវត្តមានវ៉ាដូចថា ប្រជាជនចូលចិត្តទៅវត្តទៅអីដែរ?

សារ៉េន :	ប្រជាជនធ្វើបុណ្យខ្លាំង ខ្ញុំទាំងគេធ្វើបុណ្យអស់ទាស់ហើយ ។

វណ្ណៈ :	ចឹងវត្តវ៉ានឹង វត្តនឹងកើតក្រោយសមាហរណកម្មហើយ?

សារ៉េន :	ចា៎!

វណ្ណៈ :	មុននឹងក៏តាសុន សេន មិនឲ្យធ្វើដែរ?

សារ៉េន :	អត់ឲ្យធ្វើទេ មានវត្តទេ សុទ្ធតែខ្លាំង សុទ្ធតែអីទាំងអស់ចាប់ផាប់ ។

វណ្ណៈ :	គាត់មិនឲ្យមាន?

សារ៉េន :	អត់ឲ្យមានទេ តាសុន សេន បើនិយាយឲ្យចំទមិឡអត់សាសនាចប់ ។

វណ្ណៈ :	គាត់កាច?

សារ៉េន :	កាច ។

វណ្ណៈ :	ចឹងខ្ញុំដូចជាអស់អីសួរមីងហើយ ខ្ញុំអរគុណមីងច្រើនហើយ ។

សារ៉េន :	ចា៎! អរគុណដែរ ។

វណ្ណៈ :	ដែលមីងជួយផ្តល់បទសម្ភាសន៍ឲ្យខាងខ្ញុំ ដើម្បីទុកចងក្រងឲ្យក្មេងបានដឹងបានព្វមីងណា ។

«ចប់»